# ភាពរស់កល្បជានិច្ច

## ការយល់ខុសជាយូរមកហើយ



The Wallace Legacy FOUNDATION

www.rethinketernity.com




***“ព្រះយេស៊ូវមានបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ។”***

**យ៉ូហាន ១៤:៦**

# ភាពអស់កល្បជានិច្ច

## ការយល់ខុសជាយូរមកហើយ

## រឿង៣យ៉ាងដែលព្រះមិនអាចធ្វើបាន

មិត្តអ្នកអានជាទីស្រលាញ់អើយ **ភាពអស់កល្បជានិច្ចគឺជាពេលវេលាមួយដ៏វែងដែលយើងមិនគួរយល់ខុស។** ដូច្នេះសូមអានព្រះគម្ពីរដែលជាព្រះបន្ទូលរបស់ព្រះដោយយកចិត្តទុកដាក់បំផុត ថាតើព្រះបន្ទូលរបស់ព្រះមានព្រះបន្ទូលយ៉ាងដូចម្តេចទាក់ទងនឹងទិសដៅរបស់អ្នកដ៏នៅអស់កល្បជានិច្ចបន្ទាប់ពីជីវិតនៅផែនដីនេះ។

១. ព្រះមិនអាចកុហកបាន។ ព្រះគម្ពីរមានបន្ទូលថា **“ដោយសេចក្តីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច ដែលព្រះដ៏មិនចេះភូតបានសន្យាមុនអស់ទាំងកល្ប”** -ទីតុស ១:២។

២. ព្រះមិនអាចផ្លាស់ប្រែបាន។ ព្រះគម្ពីរមានបន្ទូលថា **“ដ្បិតអញ គឺយេហូវ៉ា អញមិនប្រែប្រួលឡើយ ហេតុនោះឱពួកកូនចៅយ៉ាកុបអើយ ឯងរាល់គ្នាមិនបានត្រូវវិនាសទេ”** -ម៉ាឡាគី ៣:៦។

៣. ព្រះមិនអាចអនុញ្ញាតអោយនរណាម្នាក់ចូលទៅស្ថានសួគ៌បាននោះទេ លើកលែងតែអ្នកនោះបានកើតជាថ្មី។ ព្រះគម្ពីរបានបញ្ជាក់ថា **“ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ”** -យ៉ូហាន ៣:៣។

## ព្រះគម្ពីរបរិសុទ្ធ

**“គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែងទេ ក៏មានប្រយោជន៍សំរាប់ការបង្រៀន ការរំឭកឲ្យដឹងខ្លួន ការប្រដៅដំរង់ និងការបង្ហាត់ខាងឯសេចក្តីសុចរិត”** -១ធីម៉ូថេ ៣:៣។

នៅថ្ងៃរំលឹកខួបលើកទី១នៃការវាយប្រហាររបស់ភេរវកម្មនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ លោកថូម ឡាវីស នៃរដ្ឋចនស្មោន ប្រទេសអាមេរិក លោកបានសរសេរអត្ថបទលើការសែតមួយ។ លោកបានសរសេរថា “ប្រសិនបើពិភពលោកកំពុងស្វែងរកសញ្ញានៃក្តីសង្ឃឹមនៅក្នុងភាពចលាចលដែលបានផ្ទុះឡើងនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ នោះប្រហែលជាអាចរកឃើញហើយ។ ក្រុមអ្នកជួយសង្គ្រោះបន្ទាន់ដែលបានឆ្លើយតបទៅនឹងការធ្លាក់យន្តហោះ *Flight 93* នៅជិតរដ្ឋ *Shanksville* បានរកឃើញដ៏អស្ចារ្យមួយដែលបានធ្វើអោយពួកគេមានការភ្ញាក់ផ្អើល និងបានជំរុញទឹកចិត្តពួកគេ។ នៅមិនឆ្ងាយប៉ុន្មានពី

ភ្នំភ្លើងដែលមានជម្រៅជិត៨ម៉ែត្រ ជនស្លូតត្រង់៤០នាក់បានវិនាសបាត់ទៅ។ ក្រុមអ្នកពន្លត់អគ្គីភ័យបានរកឃើញព្រះគម្ពីរមួយក្បាលដែលមិនសូវមានគេច្រៀង។" អត្ថបទដ៏អស្ចារ្យនេះបង្ហាញថា ព្រះបានរក្សាព្រះបន្ទូលរបស់ទ្រង់នៅក្នុងពិភពលោកសហសម័យនេះ ដើម្បីអោយយើងអាចដឹងពីគំនិតរបស់ទ្រង់។ **"ដ្បិត តើអ្នកណាស្គាល់គំនិតនៃព្រះអម្ចាស់ តើអ្នកណានឹងបង្រៀនទ្រង់បាន តែយើងរាល់គ្នាមានគំនិតជារបស់ផងព្រះគ្រីស្ទវិញ"** -១កូរិនថូស ២:១៦។

អ្នករិះគន់បានព្យាយាមបង្ខូចព្រះគម្ពីរ អារក្សធ្វើអោយមានការសង្ស័យលើព្រះគម្ពីរ អ្នកស្អប់ព្រះបានប៉ុនប៉ងដុតព្រះគម្ពីរ អ្នករៀនចេះដឹងចំអកឱ្យព្រះគម្ពីរ ហើយរដ្ឋាភិបាលសហព័ន្ធរបស់យើងបានព្យាយាមដកព្រះគម្ពីរចេញពីស្ថាប័នពួកគេ។ ទោះជាយ៉ាងណាក៏ដោយ ព្រះពិតនៃស្ថានសួគ៌បានរក្សាការពារព្រះបន្ទូលទ្រង់ជារៀងរហូត! អាចនិយាយបានថាព្រះគ្រាន់តែចង់បង្ហាញពិភពលោកថា សូម្បីតែភ្លើងដែលអាចឆេះអ្វីៗក្នុងពេលតែប៉ុន្មាននាទីក៏ដោយ តែមិនអាចដុតអ្វីដែលទ្រង់បានបង្កើតជាសេចក្តីពិតបានឡើយ! **"ដ្បិតព្រះយេហូវ៉ាទ្រង់ប្រទានឲ្យមានប្រាជ្ញា ឯដំរិះនឹងយោបល់ នោះចេញពីព្រះឱស្ឋរបស់ទ្រង់មក"** -សុភាសិត ២:៦។

# ព្រះគម្ពីរគឺជាគំនិតរបស់ព្រះ តាមរយៈព្រះឱស្ឋរបស់ព្រះយេស៊ូវ

ព្រះបន្ទូលនៃព្រះបានផ្តល់នូវផែនការសំរាប់ការប្រោសលោះដល់មនុស្សទាំងអស់។ **"...អញនឹងប្រព្រឹត្តនឹងឯងរាល់គ្នាយ៉ាងនោះតទៅ...ចូររៀបចំ ដើម្បីជួបនឹងព្រះនៃខ្លួនចុះ"** -អេម៉ុស ៤:១២។

ព្រះគម្ពីរបង្ហាញថាមនុស្សត្រូវមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះនៃស្ថានសួគ៌ តាមរយៈព្រះយេស៊ូវគ្រីស្ទ (ព្រះរាជបុត្រា) ហើយត្រូវបានបញ្ជាក់នៅក្នុងចិត្តរបស់គ្រីស្ទបរិស័ទដោយព្រះវិញ្ញាណបរិសុទ្ធ។ **"ឯយើងរាល់គ្នា ជាអ្នកមកពីព្រះវិញ ហើយអ្នកណាដែលស្គាល់ព្រះនោះក៏ស្តាប់យើងខ្ញុំ តែអ្នកណាដែលមិនមកពីព្រះទេ នោះមិនព្រមស្តាប់យើងខ្ញុំឡើយ គឺយ៉ាងនោះឯងដែលយើងនឹងស្គាល់វិញ្ញាណនៃសេចក្តីពិត និងវិញ្ញាណនៃសេចក្តីខុសឆ្គងទៅបាន"** -១យ៉ូហាន ៤:៦។

មានតែគ្រិស្តបរិស័ទដ៏ពិតដែលជឿលើព្រះគម្ពីរប៉ុណ្ណោះដែលមានការធានាអំពីជីវិតដ៏នៅអស់កល្បជានិច្ចពិតប្រាកដ។ សាសនាផ្សេងៗទៀតទាមទារអំពើល្អសម្រាប់ព្រះរបស់ពួកគេ ហើយអំពើល្អរបស់ពួកគេមិនដែលគ្រប់គ្រាន់នោះទេ។


The Wallace Legacy FOUNDATION

ព្រះយេស៊ូវមានព្រះបន្ទូលថា **"អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក"** -ម៉ាថាយ ១១:២៨។

អ្នកកាន់សាសនាម្នាក់ធ្លាប់បាននិយាយថា គាត់ហើរលើស្លាបពីរ ស្លាបម្ខាងគឺស្លាបនៃក្តីសង្ឃឹម និងស្លាបម្ខាងទៀតគឺស្លាបនៃសេចក្តីភ័យខ្លាច! **"ដ្បិតព្រះទ្រង់មិនបានប្រទានឲ្យយើងមានវិញ្ញាណ ដែលតែងតែខ្លាចឡើយ គឺឲ្យមានវិញ្ញាណដ៏មានអំណាច សេចក្តីស្រឡាញ់ និងប្រាជ្ញានឹងធឹងវិញ"** -២ធីម៉ូថេ ១:៧។ ដោយសារព្រះមិនផ្តល់វិញ្ញាណនៃការភ័យខ្លាចទេ ដូច្នេះ វាត្រូវតែមកពីអារក្សសាតាំង ជាមេដែលនៅពីក្រោយការធ្វើការរបស់សាសនាទាំងអស់។ **"ដ្បិតគឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះក៏មិនមែនកើតពីអ្នករាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ"** -អេភេសូរ ២:៨-៩។ សេចក្តីសុខសាន្ត (ការសម្រាក) ដែលព្រះយេស៊ូវប្រទានមកតាមរយៈការជឿទុកចិត្តលើកិច្ចការរបស់ទ្រង់នៅលើឈើឆ្កាង គឺជាសំបុត្រសំរាប់អ្នកទៅកាន់ស្ថានសួគ៌អស់កល្បជានិច្ច គ្មានផ្លូវណាផ្សេងទៀតនោះទេ។

សូមមេត្តាកុំទាន់ឈប់អាន! បើគ្មានព្រះយេស៊ូវគ្រីស្ទនៅក្នុងជីវិតរបស់អ្នកទេ នោះអ្នកនឹងត្រូវសងសម្រាប់ថ្លៃឈ្នួលអំពើបាបផ្ទាល់ខ្លួនរបស់អ្នក។ **"ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា"** -រ៉ូម ៦:២៣។

**"តែយើងឃើញព្រះយេស៊ូវវិញ ដែលព្រះបានធ្វើឲ្យទាបជាងពួកទេវតាបន្តិច ទ្រង់ពាក់សិរីល្អ និងល្បីព្រះនាម ទុកជាមកុដ ដោយព្រោះទ្រង់បានរងទុក្ខសុគត ដើម្បីនឹងភ្លក់សេចក្តីស្លាប់ជំនួសមនុស្សទាំងអស់ ដោយនូវព្រះគុណនៃព្រះ។"**

-ហេព្រើរ ២:៩

*«ព្រះគម្ពីរគឺជាសៀវភៅសិក្សាតែមួយគត់ដែលអ្នកនិពន្ធ មានវត្តមានរាល់ពេលដែលគេសិក្សា!»*

## ព្រះត្រីឯក

សេចក្តីពិតជាមូលដ្ឋាននៃព្រះគម្ពីររបស់គ្រីស្ទបរិស័ទគឺនៅដោយសុវត្ថិភាពនៅក្នុងព្រះត្រីឯក។ **"មានសាក្សីពរអង្គដែលធ្វើបន្ទាល់នៅស្ថានសួគ៌ គឺជាព្រះវរបិតា១ ព្រះបន្ទូល១ និងព្រះវិញ្ញាណបរិសុទ្ធ១ តែទាំង៣អង្គនេះរួមមកតែ១ទេ"** -១យ៉ូហាន ៥:៧។


The Wallace Legacy FOUNDATION

ខគម្ពីរនេះផ្តល់ការធានាថា អង្គបុគ្គម្នាក់ៗនៃព្រះត្រីឯកមានលក្ខណៈដោយឡែកពីគ្នា។ អង្គបុគ្គនៃមួយៗដំណើរការដាច់ដោយឡែកពីគ្នា ប៉ុន្តែអង្គទ្រង់ទាំងបីបុគ្គមិនដែលផ្តុយពីគ្នាឡើយ។ ដោយសារព្រះមានអង្គបុគ្គបីអង្គផ្សេងគ្នា ដូច្នេះទ្រង់ត្រូវបានគេហៅថាជាព្រះត្រីឯក។

## ព្រះវរបិតា

បុគ្គលទីមួយនៃព្រះត្រីឯកគឺ**ព្រះជាវរបិតា**។ ព្រះយេស៊ូវបានពន្យល់ពីកន្លែងដែលទ្រង់បានមកថា **"ខ្ញុំបានចេញពីព្រះវរបិតាមកមែន ហើយបានមកក្នុងលោកីយ៍ ក៏នឹងចេញពីលោកីយ៍ទៅឯព្រះវរបិតាវិញទៀត"** -យ៉ូហាន ១៦:២៨។ សូមកត់សម្គាល់ពីអ្វីដែលបទគម្ពីរបញ្ជាក់ថា ព្រះដែលជាព្រះវរបិតានៅតែគង់នៅស្ថានសួគ៌ ខណៈពេលដែលព្រះយេស៊ូវបានធ្វើកិច្ចការរបស់ទ្រង់នៅលើផែនដី។ ម្យ៉ាងទៀត សូមកត់សម្គាល់លក្ខណៈមួយទៀតរបស់ព្រះដែលជាព្រះវរបិតា **"ឯព្រះ ទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ និងសេចក្តីពិតដែរ"** -យ៉ូហាន ៤:២៤។ ព្រះដែលជាព្រះវរបិតាគឺជាវិញ្ញាណ។

## ព្រះរាជបុត្រា

ព្រះរាជបុត្រាគឺជាបុគ្គលទី២នៃព្រះត្រីឯក, **"កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលក៏គង់នៅជាមួយនឹងព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ"** -យ៉ូហាន ១:១។ នៅក្នុងខគម្ពីរនេះ យើងឃើញព្រះយេស៊ូវក្លាយជាសាច់ឈាម ទ្រង់បានប្រសូតជាមនុស្សដើម្បីនឹងលោះអំពើបាបរបស់មនុស្សលោក។ **"ព្រះបន្ទូលក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណនិងសេចក្តីពិត"** -យ៉ូហាន ១:១៤។ **"ព្រះបន្ទូល"** នៅក្នុងភាសាអង់គ្លេសត្រូវបានសរសេរជាអក្សរធំដែលសំដៅទៅលើឈ្មោះព្រះយេស៊ូវ។ **"...ក៏ត្រឡប់ជាសាច់ឈាម..."** នោះគឺជាព្រះយេស៊ូវ។

ដូចដែលត្រូវបានទាយទុកមុនដោយហោរាអេសាយ ៧:១៤ ព្រះយេស៊ូវបានយាងមកផែនដីក្នុងរូបភាពជាមនុស្សតាមរយៈស្ត្រីព្រហ្មចារី។

**“ដូច្នេះព្រះអម្ចាស់ទ្រង់នឹងប្រទានទីសំគាល់១មកអ្នករាល់គ្នា ដោយព្រះអង្គទ្រង់ មើល នាងព្រហ្មចារីនឹងមានគភ៌ប្រសូតបានបុត្រា១ ហើយនឹងឲ្យព្រះនាមថា អេម៉ាញូអែល”**។ លើសពីនេះ បទគម្ពីរក៏បានបញ្ជាក់ផងដែរអំពីស្ថានភាពដ៏នៅអស់កល្បរបស់ព្រះយេស៊ូវ, **“ដ្បិតព្រះយេស៊ូវគ្រីស្ទទ្រង់នៅតែដដែល គឺពីថ្ងៃម្សិល ថ្ងៃនេះ ហើយទៅដល់អស់កល្បជានិច្ចតទៅ”** -ហេព្រើរ ១៣:៨។

ខគម្ពីរជាច្រើនទៀតបានបង្ហាញអំពីគោលលទ្ធិដែលថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះនៅក្នុងសាច់ឈាម។ នេះគឺជាឧទាហរណ៍មួយទៀតនៃការពិតនេះ, **“តែខាងឯព្រះរាជបុត្រាវិញ នោះទ្រង់មានព្រះបន្ទូលថា «ឱព្រះអើយ បល្ល័ង្កទ្រង់នៅជាប់អស់កល្បជានិច្ចរៀងរាបតទៅ ព្រះដំបងពេជ្ររបស់រាជ្យទ្រង់ នោះជាដំបងសុចរិត”** -ហេព្រើរ ១:៨។ សូមកត់សម្គាល់នៅក្នុងខគម្ពីរនេះថា ព្រះបានសំដៅទៅលើព្រះរាជបុត្រាគឺជាព្រះ។ ព្រះយេស៊ូវជារូបដើមនៃមនុស្សជាយូរមកហើយមុនការបង្កើតអ័ដាមមកម្ល៉េះ។ ព្រះគម្ពីរបានបង្ហាញថា ព្រះយេស៊ូវគឺជាផ្លូវតែមួយគត់ទៅឋានសួគ៌, **“ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត <u>បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ</u>”** -យ៉ូហាន ១៤:៦ (សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម)។ ដោយសារផលវិបាកដ៏អស់កល្បជានិច្ច វាជារឿងសំខាន់ក្នុងការយល់ពីមូលហេតុដែលព្រះយេស៊ូវមានសិទ្ធិអំណាចក្នុងការមានព្រះបន្ទូលបែបនេះ៖ **“ព្រមទាំងអរព្រះគុណ ដល់ព្រះវរបិតាដែលទ្រង់បានប្រោសឲ្យយើងបានគួរនឹងទទួលចំណែកកេរ្តិ៍អាករក្នុងពួកបរិសុទ្ធនៅទីភ្លឺផង។ ទ្រង់បានប្រោសឲ្យយើងរួចពីអំណាចនៃសេចក្តីងងឹត ហើយផ្លាស់យើងមកក្នុងនគររបស់ព្រះរាជបុត្រាស្ងួនភ្ងានៃទ្រង់។ យើងរាល់គ្នាមាន<u>សេចក្តីប្រោសលោះក្នុងព្រះរាជបុត្រានោះ</u> គឺជា<u>សេចក្តីផ្តាច់បាបដោយសារព្រះលោហិតទ្រង់</u>។ ដែល<u>ទ្រង់ជារូបអង្គនៃព្រះដ៏មើលមិនឃើញ</u> ជាបងច្បងនៃ<u>គ្រប់ទាំងអស់ដែលព្រះបានបង្កើតមក</u>។ ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់ ទាំងរបស់នៅស្ថានសួគ៌ និងនៅផែនដី ទាំងរបស់ដែលមើលឃើញ ហើយដែលមើលមិនឃើញផង ទោះបើជារាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាចណាក៏ដោយ <u>នោះសុទ្ធតែកើតមកដោយសារទ្រង់ ហើយសំរាប់ទ្រង់ទាំងអស់ផង</u>។ ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏ស្ថិតស្ថេរ ដោយសារទ្រង់។ ទ្រង់ជាសិរសារបស់រូបកាយ គឺជាពួកជំនុំ ទ្រង់ជាដើម ក៏បានរស់ពីស្លាប់ឡើងវិញមុនគេបង្អស់ ដើម្បីឲ្យទ្រង់បានជាប្រធានក្នុងគ្រប់ទាំងអស់។ ដ្បិតព្រះបានសព្វព្រះហឫទ័យ ឲ្យគ្រប់ទាំងសេចក្តីពោរពេញបានស្ថិតនៅក្នុងទ្រង់។ <u>ហើយឲ្យបានផ្សះផ្សាគ្រប់ទាំងអស់ ឲ្យជានឹងអង្គទ្រង់ ដោយសារព្រះរាជបុត្រានោះ ទោះបើរបស់នៅស្ថានសួគ៌ ឬនៅផែនដីក្តី ទាំងតាំង</u>**

**ស្ពានមេត្រី ដោយសារព្រះលោហិតនៃឈើឆ្កាងទ្រង់"** -កូល៉ុស ១:១២-២០។ (សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម) ខគម្ពីរទាំងអស់នេះបានពន្យល់ថាព្រះយេស៊ូវគឺជាអ្នកបង្កើតរបស់ទាំងអស់។ ព្រះគម្ពីរលោកុប្បត្តិ ១:១ បានមានបន្ទូលថា **"កាលដើមដំបូងឡើយព្រះបានបង្កើត..."** ដូច្នេះ ព្រះយេស៊ូវមិនមែនគ្រាន់តែជាព្រះរាជបុត្រានៃព្រះនោះទេ ប៉ុន្តែទ្រង់គឺជាព្រះ។ **"ដ្បិតគឺទ្រង់ហើយដែលបង្កើតគ្រប់ទាំងអស់..."** ដោយសារតែព្រះគម្ពីរកូល៉ុស ១:១៦បានមានព្រះបន្ទូលថា ព្រះយេស៊ូវបានបង្កើតរបស់ទាំងអស់ ហើយព្រះគម្ពីរលោកុប្បត្តិ ១:១ បានអះអាងថាព្រះបានបង្កើត, ដូច្នេះ តើព្រះយេស៊ូវជានរណា? ពិតប្រាកដណាស់ **ព្រះយេស៊ូវគឺជាព្រះ។**

លោកសាវកប៉ុលក៏បានបង្ហាញយ៉ាងច្បាស់ផងដែរថាព្រះយេស៊ូវគឺជាព្រះ។ **"ពិតប្រាកដជាសេចក្តីអាថ៌កំបាំងរបស់សាសនានៃយើង នោះជ្រាលជ្រៅណាស់ គឺដែលព្រះបានលេចមកក្នុងសាច់ឈាម បានរាប់ជាសុចរិតដោយព្រះវិញ្ញាណ ពួកទេវតាបានឃើញទ្រង់ មនុស្សបានប្រកាសប្រាប់ពីទ្រង់ដល់ពួកសាសន៍ដទៃ មានគេជឿដល់ទ្រង់ក្នុងលោកិយនេះ រួចព្រះបានលើកទ្រង់ឡើងទៅក្នុងសិរីល្អវិញ"** -១ធីម៉ូថេ ៣:១៦។

ជាថ្មីម្តងទៀត តាមរយៈការបណ្តាលដោយព្រះ លោកសាវកប៉ុលបានបញ្ជាក់ពីសេចក្តីពិតថាព្រះយេស៊ូវគឺជាព្រះ ដែលជាព្រះរាជបុត្រាសំរាប់អ្នកជឿនៅក្នុងក្រុមជំនុំក្រុងកូរិនថូស៖ **"ដូច្នេះ យើងខ្ញុំជាទូតដំណាងព្រះគ្រីស្ទ ហាក់ដូចជាព្រះទ្រង់អង្វរដោយសារយើងខ្ញុំ គឺយើងខ្ញុំអង្វរគេជំនួសព្រះគ្រីស្ទថា ចូរឲ្យបានជាមេត្រីនឹងព្រះចុះ ដ្បិតឯព្រះអង្គ ដែលមិនបានស្គាល់បាបសោះ នោះទ្រង់បានធ្វើឲ្យត្រឡប់ជាតួបាប ជំនួសយើងរាល់គ្នាវិញ ដើម្បីឲ្យយើងរាល់គ្នាបានត្រឡប់ទៅជាសេចក្តីសុចរិតរបស់ព្រះ ដោយនូវព្រះអង្គនោះឯង** (ព្រះយេស៊ូវ)" -២កូរិនថូស ៥:២០-២១។ (សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម)

មានខគម្ពីរមួយទៀតដែលបញ្ជាក់ហួសពីការសមហេតុផលនៃការសង្ស័យថាព្រះយេស៊ូជាព្រះ។ **"ដូច្នេះ ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ហើយខំថែរក្សាហ្វូងសិស្ស ដែលព្រះវិញ្ញាណបរិសុទ្ធបានតាំងអ្នករាល់គ្នា ឲ្យធ្វើជាអ្នកគង្វាលដល់គេ ដើម្បីឲ្យបានឃ្វាលពួកជំនុំរបស់ព្រះអម្ចាស់ ដែលទ្រង់បានទិញដោយព្រះលោហិតព្រះអង្គទ្រង់ចុះ"** -កិច្ចការ ២០:២៨។ (សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម)។ សូមកត់សម្គាល់ថា ព្រះបានទិញ «**ពួកជំនុំរបស់ព្រះ**» ដោយព្រះលោហិតរបស់ព្រះ ជាព្រះលោហិតនៃព្រះជាព្រះរាជបុត្រា គឺព្រះយេស៊ូវ!

ដោយសារព្រះយេស៊ូវជាព្រះ ហើយដោយសារទ្រង់បានរស់នៅដោយគ្មានបាបកាលនៅលើផែនដី ទ្រង់គឺជាបុគ្គលតែម្នាក់គត់ដែលអាច និងបានលះបង់ព្រះកាយដ៏បរិសុទ្ធរបស់ទ្រង់សម្រាប់អំពើបាបរបស់មនុស្សគ្រប់រូបដែលបានកើតមក។ **“ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោកដល់ម៉្លេះ បានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ”** -យ៉ូហាន ៣:១៦-១៧។ ដោយសារបទគម្ពីរបានមានបន្ទូលអំពីព្រះយេស៊ូវគ្រីស្ទជានរណា ហើយដោយសារទ្រង់មានបន្ទូលថាអ្នករាល់គ្នាត្រូវតែកើតជាថ្មីដើម្បីទៅស្ថានសួគ៌ វាមានសារៈសំខាន់ណាស់ក្នុងការស្វែងយល់ពីអត្ថន័យរបស់ទ្រង់នៅពេលទ្រង់មានបន្ទូលថា, **“ត្រូវតែកើតជាថ្មី”** -យ៉ូហាន ៣:៧។

# កត្តាដ៏ធំពីភាពខុសគ្នារវាងសាសនាផ្សេងទៀត និងគ្រីស្ទបរិស័ទ្ធ គឺជាការពិតដែលថាព្រះយេស៊ូវគឺជាព្រះ!

---

## ព្រះវិញ្ញាណបរិសុទ្ធ

នៅកថាខណ្ឌខាងលើ យើងបានឃើញពីសិទ្ធិអំណាចរបស់ព្រះដែលជាព្រះរាជបុត្រា។ ឥឡូវនេះ ព្រះយេស៊ូវបានអះអាងថាព្រះជាព្រះវិញ្ញាណបរិសុទ្ធ ជាបុគ្គលទីបីនៃព្រះត្រីឯក, **“តែព្រះដ៏ជាជំនួយ គឺជាព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះវរបិតានឹងចាត់មក ដោយនូវឈ្មោះខ្ញុំ ទ្រង់នឹងបង្រៀនអ្នករាល់គ្នា ពីគ្រប់សេចក្តីទាំងអស់ ក៏នឹងរំឭកពីគ្រប់ទាំងសេចក្តី ដែលខ្ញុំបានប្រាប់ដល់អ្នករាល់គ្នាដែរ”** -យ៉ូហាន ១៤:២៦។ សូមសង្កេតមើលក្នុងវខគម្ពីរនេះ បីផ្នែកផ្សេងគ្នានៃព្រះត្រីឯក ព្រះវរបិតាបានចាត់ព្រះវិញ្ញាណបរិសុទ្ធក្នុងព្រះនាមព្រះយេស៊ូវ។

បន្ទាប់មក សូមកត់សម្គាល់មើលថា ព្រះយេស៊ូវជារូបអង្គនៃព្រះដែលមើលមិនឃើញ គឺទ្រង់បានបង្រៀនសិស្សរបស់ទ្រង់អំពីការសុគត ការបញ្ចុះក្នុងផ្នូរ និងការរស់ឡើងវិញរបស់ទ្រង់ នៅពេលដែលទ្រង់បានថ្លែងថា, **“នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ១អង្គទៀតមកអ្នករាល់គ្នាឲ្យបានគង់នៅជាមួយនៅអស់កល្បជានិច្ច គឺជា**

**ព្រះវិញ្ញាណនៃសេចក្តីពិត ដែលលោកីយ៍ទទួលពុំបាន ព្រោះមិនឃើញ ហើយមិនស្គាល់ទ្រង់សោះ តែអ្នករាល់គ្នាស្គាល់ទ្រង់ ដ្បិតទ្រង់គង់ជាមួយ ក៏នឹងសណ្ឋិតនៅក្នុងអ្នករាល់គ្នាដែរ"** -យ៉ូហាន ១៤:១៦-១៧។ នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធសណ្ឋិតនៅក្នុងចិត្តនរណាម្នាក់ ទ្រង់អាចណែនាំចិត្តរបស់បុគ្គលនោះយ៉ាងងាយស្រួលក្នុងផ្លូវនៃសេចក្តីសុចរិត។ ប៉ុន្តែ ជាការពិតនោះ គឺវាអាស្រ័យទៅលើពួកគេក្នុងការជ្រើសរើសរស់នៅតាមការណែនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ឬក៏អត់។

## ត្រូវបានបង្កើតដូចជារូបអង្គទ្រង់

អ័ដាមជាមនុស្សដែលបានបង្កើតដំបូងគេដែលមានរូបភាពដូចជាព្រះយេស៊ូវ, **"ទ្រង់ក៏មានព្រះបន្ទូលថា ចូរយើងធ្វើមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង"** -លោកុប្បត្តិ ១:២៦។ **"ឲ្យដូចជារូបយើង"** និង **"ឲ្យមានភាពដូចយើង"** គឺនៅក្នុងទម្រង់ពហុវចនៈ គឺ ព្រះត្រីឯកបានបង្កើតមនុស្សមកក្នុងទម្រង់បីផ្នែកខុសគ្នា។ បន្ទាប់ពីព្រះបានសូនអ័ដាមហើយ នោះព្រះយេស៊ូវបានបញ្ចូលខ្យល់ដង្ហើមនៃជីវិតទៅក្នុងគាត់, **"ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង"** -លោកុប្បត្តិ ២:៧។ ព្រះមិនបានបង្កើតខ្យល់ដង្ហើមសំរាប់យើងនោះទេ គឺទ្រង់បានប្រទានខ្យល់ដង្ហើមរបស់ទ្រង់មកយើង។

នៅក្នុងការបិទសេចក្តីថ្លែងការនៃសំបុត្រទីមួយទៅកាន់ពួកថែស្សាឡូនីច លោកសាវកប៉ុលបាននិយាយថា, **"សូមឲ្យព្រះនៃសេចក្តីសុខសាន្ត ញែកអ្នករាល់គ្នាចេញជាបរិសុទ្ធសព្វគ្រប់ ហើយឲ្យទាំងព្រលឹងនឹងវិញ្ញាណ ហើយរូបកាយទាំងមូលបានបំរុងទុកឥតសៅហ្មង ដរាបដល់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើង ទ្រង់យាងមក"** -១ថែស្សាឡូនីច ៥:២៣។

ដូចព្រះត្រីឯក មនុស្សម្នាក់ៗក៏មានបីផ្នែកដែរ -វិញ្ញាណ (សំខាន់ជាងគេ) ព្រលឹង និងរូបកាយ។

### វិញ្ញាណ

ផ្នែកដំបូង និងសំខាន់បំផុតរបស់មនុស្សគឺវិញ្ញាណរបស់ពួកគេ។ ផ្នែកខាងវិញ្ញាណរបស់មនុស្ស គឺជាអ្វីដែលព្រះ និងមនុស្សជួបគ្នា ទំនាក់ទំនងគ្នា ប្រកបគ្នា និងជាកន្លែងដែលព្រះផ្តល់ការណែនាំផ្សេងៗសំរាប់ខាងវិញ្ញាណ។ **"តើមិនដឹងទេឬអីថា**

**រូបកាយអ្នករាល់គ្នាជាវិហារនៃព្រះវិញ្ញាណបរិសុទ្ធ ដែលអ្នករាល់គ្នាបានទទួលមកពីព្រះ ហើយអ្នករាល់គ្នាមិនមែនជារបស់ផងខ្លួនទេ"** -១កូរិនថូស ៦:១៩។ វាជារឿងមួយដែលដឹង និងជឿថាមានព្រះ ហើយវាជារឿងមួយផ្សេងទៀតក្នុងការទទួលទ្រង់ជាព្រះអង្គសង្គ្រោះរបស់អ្នក (កើតជាថ្មី), **"អ្នកជឿថា មានព្រះតែ១ នោះត្រូវហើយ ទោះទាំងពួកអារក្សក៏ជឿដូច្នោះ ព្រមទាំងព្រឺខ្លាចដែរ"** -យ៉ាកុប ២:១៩។ ព្រះវិញ្ញាណបរិសុទ្ធដែលរស់នៅក្នុងអ្នកជឿនឹងដឹកនាំគាត់នៅក្នុងផ្លូវនៃសេចក្តីសុចរិត, **"កាលណាព្រះអង្គនោះ គឺជាព្រះវិញ្ញាណនៃសេចក្តីពិតបានមកដល់ នោះទ្រង់នឹងនាំអ្នករាល់គ្នាចូលក្នុងគ្រប់ទាំងសេចក្តីពិត.."** -យ៉ូហាន ១៦:១៣។

**វិញ្ញាណ**ដែលនៅក្នុងមនុស្សគឺជាផ្នែកដែលទាក់ទងជាមួយព្រះនៅក្នុងទាំងអស់បញ្ហាខាងវិញ្ញាណ, **"ឯព្រះ ទ្រង់ជាវិញ្ញាណ ហើយអ្នកណាដែលថ្វាយបង្គំទ្រង់ នោះត្រូវតែថ្វាយបង្គំ ដោយវិញ្ញាណ និងសេចក្តីពិតដែរ"** -យ៉ូហាន ៤:២៤។ វិញ្ញាណដែលស្លាប់មិនអាចទំនាក់ទំនងជាមួយព្រះដែលមានព្រះជនរស់បាននោះទេ, **"ប៉ុន្តែ មនុស្សខាងសាច់ឈាម** (អ្នកមិនជឿ) **គេមិនទទួលសេចក្តីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតគ្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ"** -១កូរិនថូស ២:១៤ (សូមសំគាល់ពាក្យដែលនៅក្នុងរង្វង់ក្រចក)។ នៅពេលដែលមនុស្សម្នាក់បានឮផែនការនៃសេចក្តីសង្គ្រោះដ៏សាមញ្ញរបស់ព្រះ នោះឱកាសដើម្បីអញ្ជើញព្រះយេស៊ូវចូលក្នុងជីវិតរបស់ពួកគេ ដើម្បីជួយសង្គ្រោះពួកគេអោយរួចផុតពីការកាត់ទោសអស់កល្បជានិច្ច ហើយផ្តល់ឱ្យពួកមានជីវិតអស់កល្បជានិច្ចនៅក្នុងស្ថានសួគ៌ នោះពួកគេអាចនឹងត្រូវទទួលយក ឬពួកគេអាចនឹងបដិសេធ។ ប្រសិនបើជម្រើសរបស់គេគឺទទួលយកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ នោះវិញ្ញាណរបស់ពួកគេនឹងរស់ឡើងក្នុងរំពេចនោះ។ **"ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ"** -រ៉ូម ៨:១៦។ ប្រសិនបើពួកគេបដិសេធ អណ្តាតភ្លើងនៃឋាននរកកំពុងរង់ចាំពួកគេ -ជឿឬមិនជឿ។ **"តែខ្ញុំខ្លាចក្រែងគំនិតអ្នករាល់គ្នា ត្រូវបង្ខូចចេញពីសេចក្តីទៀងត្រង់ខាងឯព្រះគ្រីស្ទ ដូចជាសត្វពស់បានបញ្ឆោតនាងអេវ៉ា ដោយឧបាយកលយ៉ាងនោះដែរ"** -២កូរិនថូស ១១:៣។ សេចក្តីសង្គ្រោះសំរាប់ការអស់កល្បជានិច្ចគឺងាយស្រួល, ព្រះយេស៊ូវបានធ្វើជាផ្លូវ អ្វីដែលអ្នកត្រូវធ្វើគឺគ្រាន់តែជឿ និងទទួលយកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់អ្នកតែប៉ុណ្ណោះ។ ជម្រើសគឺជារបស់អ្នក!


The Wallace Legacy FOUNDATION

## រូបកាយ

រូបកាយគឺជារឿងតិចតួចដែលត្រូវពន្យល់ វា -គឺគ្រាន់តែជារូបរាងរបស់យើង។ រូបកាយរបស់យើងគឺជាផ្ទះសំរាប់វិញ្ញាណ និងព្រលឹងរបស់យើង ក្នុងខណៈពេលដែលយើងនៅមានដង្ហើមដកនៅឡើយ។ ព្រះបានផ្តល់ឱ្យយើងនូវរយៈពេលខ្លីក្នុងរូបកាយនៅផែនដីរបស់យើងដើម្បីឱ្យយើងអាចគិតពិចារណាពីកន្លែងដែលយើង នឹងចំណាយពេលអស់កល្បជានិច្ចបន្ទាប់ពីជីវិតនៅផែនដីនេះ។ ប្រសិនបើព្រះបង្ខំមនុស្សឱ្យជឿ នោះទ្រង់នឹងក្លាយជាបុគ្គល ផ្តាច់ការដែលលេងជាមួយនឹងការបង្កើតរបស់ទ្រង់។ ការពិតនោះគឺថា ទ្រង់នឹងប្រើព្រះគម្ពីរ ដែលជាព្រះបន្ទូលដ៏បរិសុទ្ធរបស់ទ្រង់ដើម្បីបង្ហាញអ្នកពីរបៀបក្នុងការក្លាយកូនរបស់ទ្រង់។ **"ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ"** -យ៉ូហាន ១:១២។ មនុស្សជាច្រើនគិតថាយើងទាំងអស់គ្នាជាកូនរបស់ព្រះ។ នេះគ្រាន់តែជាការគិតប្រាថ្នាចង់បានតែប៉ុណ្ណោះ។ បើយោងតាមខគម្ពីរនេះ មនុស្សម្នាក់អាចក្លាយជាកូនរបស់ព្រះបាន គឺបន្ទាប់ពីទទួលព្រះយេស៊ូវជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់គាត់, **"ដ្បិតអ្នករាល់គ្នាសុទ្ធតែជាកូនព្រះ ដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវ"** -កាឡាទី ៣:២៦។ ព្រះគម្ពីរបានបង្ហាញយ៉ាងច្បាស់ណាស់អំពីអ្នកណាជាឪពុករបស់អ្នកដែលមិនជឿទាំងអស់។ ព្រះយេស៊ូវកំពុងតែមានការពិភាក្សាជាមួយនឹងអ្នកដឹកនាំសាសនានៅសម័យនោះ នៅពេលដែលទ្រង់បានកត់ត្រាសេចក្តីពិតបែបដូចនេះ៖ **"ព្រះយេស៊ូវមានព្រះបន្ទូលថា បើព្រះជាព្រះវរបិតានៃអ្នករាល់គ្នាមែន នោះអ្នកនឹងបានស្រឡាញ់ខ្ញុំ ដ្បិតខ្ញុំចេញពីព្រះមក ហើយក៏មកដល់ មិនមែនមកដោយអាងខ្លួនខ្ញុំទេ គឺព្រះអង្គបានចាត់ឲ្យខ្ញុំមកទេតើ។ ហេតុអ្វីបានជាអ្នករាល់គ្នាមិនយល់សំដីខ្ញុំ គឺមកតែពីស្តាប់ពាក្យខ្ញុំមិនបានប៉ុណ្ណោះ។ អ្នករាល់គ្នាមានអារក្សសាតាំងជាឪពុក ហើយអ្នករាល់គ្នាចូលចិត្តធ្វើតាមតណ្ហា ដែលគាប់ចិត្តដល់ឪពុករបស់អ្នក វាជាអ្នកសំឡាប់គេតាំងពីដើមមក វាមិនបាននៅជាប់ក្នុងសេចក្តីពិត ព្រោះគ្មានសេចក្តីពិតនៅក្នុងវាទេ កាលណាវាពោលពាក្យភូតភរ នោះដុះចេញអំពីចិត្តវាមក ដ្បិតវាជាអ្នកកំភូត ហើយជាឪពុកនៃសេចក្តីនោះឯង"** -យ៉ូហាន ៨:៤២-៤៤

## ព្រលឹង

ព្រលឹងគឺជាអ្នកពិតប្រាកដ។ វាជាចិត្តគំនិតរបស់អ្នក ឆន្ទៈរបស់អ្នក បញ្ញារបស់អ្នក គឺកន្លែងដែលអ្នកធ្វើការសម្រេចចិត្ត។

ភ្នែកគឺជាឧបករណ៍រូបវន្តដែលប្រមូលផ្តុំពន្លឺ ប៉ុន្តែព្រលឹងរបស់អ្នកដាក់អ្វីៗទាំងអស់រួមគ្នាដើម្បីផ្តល់ឱ្យអ្នកនូវចក្ខុវិស័យនៃវត្ថុ។ ព្រលឹងអ្នកគឺជាកន្លែងដែលអ្នកមានអារម្មណ៍ ចេះឈឺ និងជាកន្លែងដែលអ្នកបង្ហាញពីការព្រួយបារម្ភចំពោះអ្នកដទៃ។ ការចងចាំរបស់អ្នកក៏ជាផ្នែកមួយនៃព្រលឹងរបស់អ្នក។ លូក ១៦:១៩-៣១ ប្រាប់អំពីរឿងរបស់បុរសពីរនាក់; ម្នាក់ជាអ្នកសុំទានក្រីក្រ ដែលមានឈ្មោះថា "**ឡាសារ**" និងមួយទៀត គេស្គាល់ថាជា "**បុរសអ្នកមាន**។" ឡាសារមិនបានទៅស្ថានសួគ៌ ដោយសារគាត់ជាអ្នកសុំទានក្រីក្រនោះទេ ប៉ុន្តែគាត់បានទៅដោយសារតែគាត់បានកើតជាថ្មី។

**“មានបុរសម្នាក់មានទ្រព្យសម្បត្តិច្រើន គាត់ស្លៀកពាក់សំពត់ពណ៌ស្វាយ នឹងសំពត់ទេសឯកយ៉ាងម៉ដ្ត តែងតែស៊ីលៀងដ៏ឧត្តមប្រសើររាល់តែថ្ងៃ។ ក៏មានបុរសក្រម្នាក់ ឈ្មោះឡាសារ កើតដំបៅពេញទាំងខ្លួន គេនាំយកមកផ្តេកនៅមាត់ទ្វាររបស់អ្នកមាននោះ។ គាត់មានប្រាថ្នាចង់ចំអែតពោះ ដោយចំណិតដែលធ្លាក់ចុះពីតុអ្នកមានមកណាស់ ក៏មានឆ្កែមកលិទ្ធដំបៅគាត់ដែរ។ ចំណេរក្រោយមក អ្នកក្រនោះក៏ស្លាប់ទៅ ហើយពួកទេវតានាំយកគាត់ទៅដាក់នៅស្ថានបរមសុខ នាដើមទ្រូងលោកអ័ប្រាហាំ ឯអ្នកមាននោះក៏ស្លាប់ទៅដែរ ហើយគេនាំយកទៅកប់**(រូបកាយខាងសាច់ឈាមត្រូវបានយកទៅកប់)។ **គាត់រងទុក្ខវេទនា នៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ងើបភ្នែកឡើង**(ការឈឺចាប់) **ឃើញលោកអ័ប្រាហាំពីចំងាយ**(ចក្ខុវិស័យ) **និងឡាសារនៅដើមទ្រូងលោក។ នោះគាត់ស្រែកឡើងថា ឱលោកអ័ប្រាហាំ ជាឪពុកអើយ សូមអាណិតមេត្តាខ្ញុំផង សូមឲ្យឡាសារមកជ្រលក់ចុងម្រាមដៃទៅក្នុងទឹក ដាក់លើអណ្តាតខ្ញុំឲ្យត្រជាក់បានបន្តិចផង ដ្បិតខ្ញុំវេទនានៅក្នុងភ្លើងនេះ។ តែលោកអ័ប្រាហាំឆ្លើយថា** (គាត់អាចស្តាប់ឮលោកអ័ប្រាហាំ) **កូនអើយ ចូរនឹកចាំថា**(ការចងចាំ) **កាលឯងនៅរស់នៅឡើយ ឯងបានទទួលសុទ្ធតែសេចក្តីល្អ ឯឡាសារគាត់បានតែសេចក្តីអាក្រក់ទេ ឥឡូវនេះ គាត់បានសេចក្តីកំសាន្តចិត្តវិញ ហើយឯងត្រូវវេទនា។ មួយវិញសោតមានជង្ហុកមួយយ៉ាងធំតាំងនៅជាកណ្តាលយើង ហើយនិងឯងរាល់គ្នា បានជាអស់អ្នកណាដែលចង់ឆ្លងពីទីនេះទៅឯឯង ឬពីនោះមកឯយើង នោះមិនបានឡើយ។ គាត់ក៏និយាយថា លោកឪពុកអើយ បើដូច្នេះ សូមលោកចាត់ឲ្យគាត់ទៅឯផ្ទះឪពុកខ្ញុំបន្តិច។ ដ្បិតខ្ញុំមានបងប្អូន៥នាក់ សូមឲ្យគាត់ទៅធ្វើបន្ទាល់ប្រាប់គេផង ក្រែងលោគេភ្លាត់មកក្នុងស្ថានវេទនានេះដែ**(ការព្រួយបារម្ភចំពោះអ្នកដទៃ)។ **លោកអ័ប្រាហាំឆ្លើយថា គេមានលោកម៉ូសេ និងពួកហោរាហើយ ចូរឲ្យគេស្តាប់តាមលោកទាំងនោះចុះ។ តែគាត់ប្រកែកថា ទេ លោកអ័ប្រាហាំ ឪពុកអើយ បើមានអ្នកណាពីពួកមនុស្សស្លាប់ទៅឯគេវិញ នោះគេនឹងប្រែចិត្តជាមិនខាន។ លោកឆ្លើយទៅថា បើគេមិនព្រមស្តាប់លោកម៉ូសេ និងពួកហោរាទេ នោះទោះបើមានអ្នកណារស់ពីស្លាប់ឡើងវិញក៏**

**ដោយ គង់តែគេមិនព្រមជឿដែរ"** -លូកា ១៦:១៩-៣១ (សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម និងការពន្យល់បន្ថែមដែលមាននៅក្នុងរង្វង់ក្រចក)។

ដំណើររឿងរបស់ឡាសារ និងបុរសអ្នកមាននេះគឺជារឿងដែលប្រាប់ពីសេចក្តីពិតជាក់ស្តែងក្នុងព្រះគម្ពីរដែលនិយាយពីកន្លែងសំរាប់ការដាក់ទណ្ឌកម្មដ៏អស់កល្បជានិច្ច។ ការពិតដែលព្រះយេស៊ូវបានកត់ត្រាឈ្មោះឡាសារជាភស្តុតាងថានេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រពិតប្រាកដ ហើយវាមិនមែនជារឿងប្រៀបធៀបនោះទេ។

សូមកត់សម្គាល់ព្រឹត្តិការណ៍ដែលបានកត់ត្រាទុកសម្រាប់យើងនៅក្នុងខគម្ពីរទាំងនេះ៖

១. បុរសអ្នកមានបានស្លាប់ ហើយគេបញ្ចុះក្នុងផ្នូរ។

២. ខណៈពេលដែលសពរបស់គាត់(រូបកាយ)កំពុងស្ថិតនៅក្នុងផ្នូរនៅឡើយ យើងឃើញថា បុរសអ្នកមាននៅតែអាចមើលឃើញ ស្តាប់បាន មានការចងចាំ អារម្មណ៍ឈឺចាប់ ហើយគាត់បង្ហាញសេចក្តីអាណិតអាសូរចំពោះគ្រួសារបាត់បង់របស់គាត់ដែលកំពុងនៅផែនដីនៅឡើយ។

៣. នៅពេលដែលគាត់ស្លាប់ ព្រលឹងដ៏អស់កល្បរបស់គាត់ ដែលជាផ្នែកមួយរបស់មនុស្សដែលមានអារម្មណ៍ សមត្ថភាពក្នុងការមើលឃើញ ចេះស្តាប់ ចេះគិត មានអារម្មណ៍ឈឺចាប់ និងមានការអាណិតអាសូរចំពោះអ្នកដែលបាត់បង់នោះ ត្រូវបានទទួលការរងទុក្ខភ្លាមៗ។

៤. ខទី ២៣ បញ្ជាក់យ៉ាងច្បាស់ថា គាត់មានការចងចាំបានយ៉ាងល្អ។ គាត់បានហៅឈ្មោះរបស់អ្នកសុំទាន។ បុរសអ្នកមានដែលមិនបានបញ្ចេញឈ្មោះនោះ គឺបានផ្តល់សេចក្តីពិតដ៏អស់កល្បមួយទាក់ទងនឹងអ្នកដែលជ្រើសរើសបដិសេធព្រះយេស៊ូវ៖ **"ដូច្នេះមើល អញនឹងភ្លេចឯងរាល់គ្នាអស់រលីង ហើយនឹងបោះបង់ចោលឯងរាល់គ្នាឆ្ងាយពីមុខអញទៅព្រមទាំងទីក្រុងដែលអញបានឲ្យដល់ឯង និងពួកព្ធយុកោឯងផង"** -យេរេមា ២៣:៣៩។ ស្ថានសួគ៌មិនអាចជាកន្លែងថ្វាយបង្គំ និងមានអំណរទេ ប្រសិនបើយើងដឹងថាមនុស្សជាទីស្រឡាញ់របស់យើងនៅក្នុងឋាននរក។ ពួកគេនឹងត្រូវលុបចោលពីការចងចាំរបស់យើង ហើយកាន់តែអាក្រក់ទៅទៀតនោះ គឺពីព្រះ! **"សូមឲ្យគេបានលុបចេញពីបញ្ជីជីវិតទៅកុំឲ្យកត់នៅជាមួយនឹង**


The Wallace Legacy FOUNDATION

**ពួកមនុស្សសុចរិតឡើយ”** -ទំនុកដំកើង ៦៩:២៨។ នៅពេលដែលមនុស្សមានបាបដាក់ជំនឿលើព្រះគ្រីស្ទតែមួយគត់សម្រាប់សេចក្តីសង្គ្រោះ ឈ្មោះរបស់ពួកគេនឹងត្រូវបានកត់ត្រាទុកនៅក្នុងសៀវភៅជីវិត។ សៀវភៅនេះកត់ត្រាការកក់ទុកនៅស្ថានសួគ៌អស់កល្បជានិច្ចៈ **“នោះខ្ញុំឃើញមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច គេឈរនៅចំពោះព្រះ បញ្ជីក៏បានបើកឡើង ហើយបញ្ជី១ទៀត គឺជាបញ្ជីជីវិតបានបើកឡើងដែរ រួចមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជំរះ ពីសេចក្តីដែលកត់ទុកក្នុងបញ្ជីទាំងនោះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន។ ឯសមុទ្រ នោះបានប្រគល់ពួកមនុស្សស្លាប់ ដែលនៅក្នុងទឹកមកវិញ ហើយសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ប្រគល់ពួកមនុស្សស្លាប់ ដែលនៅឯណោះមកវិញដែរ រួចគេត្រូវជំនុំជំរះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន។ ចំណែកសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្តីស្លាប់ទី២។ បើអ្នកណាគ្មានឈ្មោះកត់ទុកក្នុងបញ្ជីជីវិត អ្នកនោះត្រូវបោះទៅក្នុងបឹងភ្លើង”** -វិវរណៈ ២០:១២-១៥។

មានតែអ្នកដែលមិនបានទទួលអំណោយឥតគិតថ្លៃនៃជីវិតអស់កល្បជានិច្ចខាងវិញ្ញាណតែប៉ុណ្ណោះដែលនឹងទទួលការកាត់ទោសសម្រាប់អំពើបាបរបស់ពួកគេដែលបានកត់ត្រាក្នុងសៀវភៅផ្សេងទៀត, **“អ្នកណាដែលរៀរបង់ចោលខ្ញុំ ហើយមិនទទួលពាក្យខ្ញុំ អ្នកនោះមានចៅក្រមដែលកាត់ទោសខ្លួនហើយ គឺជាពាក្យដែលខ្ញុំបាននិយាយនោះឯង ពាក្យនោះនឹងកាត់ទោសដល់គេ នៅថ្ងៃចុងបំផុត”** -យ៉ូហាន ១២:៤៨។ សម្រាប់គ្រីស្ទបរិស័ទដែលបានកើតជាថ្មី អំពើបាបទាំងអស់របស់ពួកគេត្រូវបានបង់ថ្លៃអោយដោយព្រះលោហិតរបស់ព្រះយេស៊ូវ, **“នោះទ្រង់បានបន្ថែមនូវព្រះបន្ទូលនេះទៀតថា «អញនឹងលែងនឹកចាំពីអំពើបាប និងសេចក្តីទទឹងច្បាប់របស់គេទៀត»”** -ហេព្រើរ ១០:១៧។ យោងទៅតាមបទគម្ពីរ ពួកគេបានបញ្ចុះសពបុរសអ្នកមាន ហើយព្រលឹងគាត់បានទៅឋាននរកភ្លាមៗ។ រូបកាយ និងព្រលឹងរបស់គាត់បានញែកបែកចេញពីគ្នារហូតដល់ការកាត់ទោសចុងក្រោយ។ បន្ទាប់មក នៅពេលថ្ងៃជំនុំជំរះមកដល់ ព្រលឹងនិងរូបកាយរបស់គាត់នឹងរួបរួមគ្នាឡើងវិញ ហើយឈរចំពោះបល្ល័ង្កសដ៏អស្ចារ្យរបស់ព្រះសំរាប់ការកាត់ទោស, **“ឯសមុទ្រ នោះបានប្រគល់ពួកមនុស្សស្លាប់**(រូបកាយសាច់ឈាម)**ដែលនៅក្នុងទឹកមកវិញ ហើយសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ប្រគល់ពួកមនុស្សស្លាប់**(ព្រលឹងដែលរស់នៅឋាននរក)


The Wallace Legacy FOUNDATION

**ដែលនៅឯណោះមកវិញដែរ រួចគេត្រូវជំនុំជំរះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន"** -វិវរណៈ ២០:១៣ (សូមមើលការពន្យល់ដែលមាននៅក្នុងរង្វង់ក្រចក) នៅពេលការកំណត់បានមកដល់ហើយ នោះទ្រង់នឹងចាប់ផ្តើមអនុវត្តទោសដ៏នៅអស់កល្បជានិរន្តរ គឺបឹងភ្លើងនៅឋាននរក, **"ចំណែកសេចក្តីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្តីស្លាប់ទី២"** -វិវរណៈ ២០:១៤។

ព្រលឹងរបស់មនុស្សគឺមានតម្លៃណាស់នៅចំពោះព្រះ, **"ប៉ុន្តែព្រះទ្រង់នឹងលោះព្រលឹងខ្ញុំ ឲ្យរួចពីអំណាចនៃស្ថានឃុំព្រលឹងមនុស្សស្លាប់នោះវិញ ដ្បិតទ្រង់នឹងទទួលខ្ញុំទុក"** -ទំនុកដំកើង ៤៩:១៥។ ជាអកុសល មនុស្សជាច្រើនបានដឹកនាំជីវិតដ៏អាក្រក់បំផុត។ អ្នកខ្លះថែមទាំងអះអាងថាបានលក់ព្រលឹងរបស់ពួកគេទៅអារក្ស។ នេះបានធ្វើឲ្យពួកគេជឿថា ព្រះមិនអត់ទោសឲ្យពួកគេទេ ប៉ុន្តែការពិត ព្រលឹងមិនមែនជារបស់បុគ្គលណាម្នាក់នោះទេ វាជាកម្មសិទ្ធិរបស់ព្រះ, **"មើល ព្រលឹងទាំងអស់ជារបស់ផងអញ ទោះទាំងព្រលឹងនៃឪពុក និងព្រលឹងនៃកូនផង ក៏ជារបស់ផងអញដូចគ្នា ឯព្រលឹងណាដែលធ្វើបាប គឺព្រលឹងនោះឯងនឹងត្រូវស្លាប់វិញ"** -អេសេគាល ១៨:៤។

អ្នកមិនអាចលក់របស់អ្វីមួយដែលមិនមែនជារបស់អ្នកបានទេ ដរាបណាមនុស្សម្នាក់នៅតែមានខ្យល់ដង្ហើម ពួកគេអាចក្លាយជាកូនរបស់ព្រះ។ អំពើបាបបាននាំមកនូវសេចក្តីស្លាប់ ប៉ុន្តែព្រះយេស៊ូវបានយាងមកដើម្បីប្រោសអោយមានជីវិត។ លោកសាវកប៉ុលបានមានប្រសាសន៍ថា, **"ពាក្យនេះគួរជឿ ហើយគួរទទួលគ្រប់យ៉ាង គឺថា ព្រះគ្រីស្ទយេស៊ូវទ្រង់បានយាងមកក្នុងលោកីយ៍ ដើម្បីនឹងជួយសង្គ្រោះមនុស្សមានបាប ដែលខ្ញុំនេះជាលេខ១ក្នុងពួកគេ"** -១ធីម៉ូថេ ១:១៥។ ដោយសារសេចក្តីស្រឡាញ់របស់ព្រះចំពោះមនុស្សមានបាប ទ្រង់បានផ្តល់ឱកាសដល់សាវកប៉ុលដើម្បីកើតជាថ្មី ។ មុននឹងប្រែចិត្តទទួលព្រះគ្រីស្ទ ប៉ុលបានរស់នៅដោយការសម្លាប់ និងបៀតបៀនពួកគ្រីស្ទាន។ បន្ទាប់ពីបានកើតជាថ្មី ព្រះបានប្រើគាត់ឱ្យសរសេរចុះស្ទើរតែពាក់កណ្តាលនៃគម្ពីរសញ្ញាថ្មី។ សូមស្តាប់ទីបន្ទាល់របស់គាត់ដោយយកចិត្តទុកដាក់៖ **"សូម្បីទូលបង្គំក៏បានគិតស្មានថា គួរឲ្យទូលបង្គំធ្វើទាស់ទទឹងជាច្រើន ដល់ព្រះនាមព្រះយេស៊ូវ ពីស្រុកណាសារ៉ែតដែរ។ គឺទូលបង្គំបានធ្វើការទាំងនោះនៅក្រុងយេរូសាឡិម**

**បានទាំងចាប់ពួកអ្នកបរិសុទ្ធជាច្រើនយកទៅដាក់គុក ដោយទទួលអំណាចពីពួកសង្គ្រាជមក ហើយកាលគេសំឡាប់អ្នកទាំងនោះ ទូលបង្គំក៏យល់ព្រមដែរ។ ទូលបង្គំបានធ្វើទោសគេជាញឹកញយ នៅគ្រប់ទាំងសាលាប្រជុំ ទាំងបង្ខំឲ្យគេពោលពាក្យប្រមាថដល់ព្រះផង ហើយដោយព្រោះទូលបង្គំមានចិត្តក្តៅក្រហាយជ្រុលពេក ទាស់នឹងគេដូច្នេះ បានជាទូលបង្គំធ្វើទុក្ខបៀតបៀនដល់គេ រហូតដល់ក្រុងនៃសាសន៍ដទៃផង”** -កិច្ចការ ២៦:៩-១១។

កុំយកព្រះដាក់ក្នុងប្រអប់! មិនថាមនុស្សទាំងឡាយបានធ្វើអ្វីក៏ដោយ មិនមែនមានន័យថាព្រះយេស៊ូវមិនអាចអត់ទោសអោយបាននោះទេ។ ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សមានបាប! សូមកុំជឿពាក្យកុហករបស់អារក្ស។ អ្នកអាចក្លាយជាកូនរបស់ព្រះនៅពេលនេះបាន។ ការបដិសេធព្រះយេស៊ូវ មានន័យថាអ្នកបានជ្រើសរើសទទួលយកការកាត់ទោសដ៏នៅអស់កល្បជានិច្ចហើយ។ ដូច្នេះ កំពុងរង់ចាំអីទៀត អំពាវនាវរកទ្រង់នៅថ្ងៃនេះ, **“ដ្បិតទ្រង់មានព្រះបន្ទូលថា «នៅវេលាដែលគាប់ចិត្តដល់អញ នោះអញបានស្តាប់ឯង ហើយក្នុងថ្ងៃសង្គ្រោះ នោះអញបានជួយឯង» មើលឥឡូវនេះជាវេលាដែលគាប់ព្រះហឫទ័យទ្រង់ មើល ថ្ងៃនេះជាថ្ងៃសង្គ្រោះហើយ”** -២កូរិនថុស ៦:២។

# ការមិនជឿអំពីឋាននរកនឹងមិនអាចផ្លាស់ប្តូរការពិតរបស់វាបានទេ!

## ភាពអស់កល្បអាចជាពេលវេលាយូរក្នុងការធ្វើខុស, ប៉ុន្តែវាអាចជាពេលវេលាយូរផងដែរដើម្បីធ្វើឱ្យត្រូវ!

នៅគ្រប់ពេលវេលា ឬទីកន្លែងណាមួយក៏បាន អ្នកអាចទទួលយកសេចក្តីសង្គ្រោះដ៏អស់កល្បជានិច្ចបាន ដោយអ្នកគ្រាន់តែអធិដ្ឋានតាមសេចក្តីអធិដ្ឋាននេះ, ឱព្រះអម្ចាស់អើយ ទូលបង្គំដឹងថា ទូលបង្គំជាមនុស្សមានបាប ដែលត្រូវកាត់ទោសទៅកាន់ឋាននរក។ ទូលបង្គំសូមព្រះអង្គអត់ទោសអំពើបាបរបស់ទូលបង្គំផង។ ទូលបង្គំជឿថាព្រះយេស៊ូវជារាជបុត្រានៃព្រះ ដែលបាន


The Wallace Legacy FOUNDATION

សុគតនៅលើឈើឆ្កាង ហើយបានរស់ឡើងវិញសម្រាប់ទូលបង្គំ។ សូមអភ័យទោសដល់ទូលបង្គំផង។ សូមយាងចូលមកក្នុងចិត្តរបស់ទូលបង្គំ ហើយជួយទូលបង្គំអោយរស់នៅប្រកបដោយជីវិតដែលគាប់ដល់ព្រះហឫទ័យទ្រង់។ ទូលបង្គំសូមទទួលយកទ្រង់ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់ទូលបង្គំ។ សូមអរព្រះគុណទ្រង់ដែលបានកត់ត្រាឈ្មោះរបស់ទូលបង្គំនៅក្នុង**សៀវភៅជីវិត**។ ទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវ អាម៉ែន។

**"ខ្ញុំបានជាប់ឆ្កាងជាមួយនឹងព្រះគ្រីស្ទ ប៉ុន្តែខ្ញុំរស់នៅ មិនមែនជាខ្ញុំទៀត គឺជាព្រះគ្រីស្ទទ្រង់រស់ក្នុងខ្ញុំវិញ ហើយដែលខ្ញុំរស់ក្នុងសាច់ឈាមឥឡូវនេះ នោះគឺរស់ដោយសេចក្តីជំនឿ ជឿដល់ព្រះរាជបុត្រានៃព្រះ ដែលទ្រង់ស្រឡាញ់ខ្ញុំ ក៏បានប្រគល់ព្រះអង្គទ្រង់ជំនួសខ្ញុំហើយ។ ខ្ញុំមិនលើកព្រះគុណនៃព្រះចោលទេ ដ្បិតបើសិនជាសេចក្តីសុចរិតមកដោយសារក្រឹត្យវិន័យ នោះព្រះគ្រីស្ទបានសុគតជាឥតប្រយោជន៍សោះ"** -កាឡាទី ២:២០-២១។

**សូមព្យាយាមអានបន្តដើម្បីស្វែងយល់បន្ថែមអំពី ការកើតជាថ្មីមានន័យយ៉ាងដូចម្តេច!**

## អ្នកត្រូវតែកើតជាថ្មី គឺជាកំណើតទីពីរ

គោលបំណងច្បាស់លាស់នៃព្រះបន្ទូលរបស់ព្រះគឺសម្រាប់អោយមនុស្សទាំងអស់ដឹង ថាតើព្រះជានរណា និងធ្វើយ៉ាងណាដើម្បីអោយមានជីវិតអស់កល្បជានិច្ចជាមួយទ្រង់។ នៅក្នុងព្រះគម្ពីរយ៉ូហានជំពូក៣ ព្រះយេស៊ូវគ្រីស្ទដែលជាព្រះនៅពេលដែលទ្រង់នៅក្នុងសាច់ឈាមនៅឡើយ ទ្រង់បានសន្ទនាអំពីបញ្ហានេះជាមួយលោកនីកូដេម ដែលជាអ្នកកាន់សាសនា និងជាមេសាសន៍យូដា។ ព្រះយេស៊ូវបានប្រាប់គាត់យ៉ាងច្បាស់ថាត្រូវធ្វើយ៉ាងណាដើម្បីទៅស្ថានសួគ៌, **"ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតជាថ្មី នោះគ្មានអ្នកណាអាចនឹងឃើញនគរព្រះបានទេ"** -យ៉ូហាន ៣:៣។ លោកនីកូដេមមិនបានយល់អំពីសេចក្តីពិតខាងវិញ្ញាណទាក់ទងនឹងការកើតជាថ្មីទេ ដូច្នេះ គាត់សួរសំណួរមួយដល់ព្រះយេស៊ូវ, **"...ធ្វើដូចម្តេចនឹងកើតឡើងបាន ក្នុងកាលដែលចាស់ហើយ តើអាចនឹងចូលទៅក្នុងពោះម្តាយម្តងទៀត ហើយកើតឡើងវិញបានឬ"** -យ៉ូហាន ៣:៤។


The Wallace Legacy FOUNDATION

ដោយសារតែការសន្ទនាគឺអំពីខាងវិញ្ញាណ ដូច្នេះ លោកនីកូដេម មិនអាចយល់ពីអ្វីដែលព្រះយេស៊ូវទ្រង់មានបន្ទូលទេ។ ព្រះគម្ពីរពន្យល់ពីមូលហេតុដែលគាត់មិនអាចយល់អំពីចម្លើយរបស់ព្រះយេស៊ូវទាក់ទងនឹងការពិតខាងវិញ្ញាណ, **"ប៉ុន្តែ មនុស្សខាងសាច់ឈាម**(អ្នកដែលមិនជឿ)**គេមិនទទួលសេចក្ដីខាងឯព្រះវិញ្ញាណនៃព្រះទេ ពីព្រោះជាសេចក្តីល្ងង់ល្ងើដល់គេ ក៏រកស្គាល់មិនបានដែរ ដ្បិតគ្រង់ឯសេចក្តីទាំងនោះ ត្រូវពិចារណាយល់ខាងវិញ្ញាណវិញ"** -១កូរិនថុស ២:១៤។ ផ្នែកខាងវិញ្ញាណរបស់មនុស្សត្រូវតែត្រូវបានធ្វើឱ្យមានជីវិតរស់ឡើងវិញ(កើតជាថ្មី)ដើម្បីយល់ពីសេចក្ដីពិតទាំងនេះ។

បន្ទាប់ពីនីកូដេមបានសួរសំណួរនោះ ព្រះយេស៊ូបានពន្យល់ ដល់គាត់នូវកំណើតពីរដែលត្រូវតែមានវត្តមាននៅក្នុងជីវិតរបស់គាត់ដើម្បីអោយបានទៅឋានសួគ៌៖**"ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយថា ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ។ របស់អ្វីដែលកើតពីសាច់ នោះជាសាច់ទេ ហើយដែលកើតពីព្រះវិញ្ញាណ នោះជាវិញ្ញាណវិញ។ កុំឲ្យឆ្ងល់ ពីពាក្យដែលខ្ញុំប្រាប់ថា ត្រូវតែកើតជាថ្មីនោះឡើយ"** -យ៉ូហាន ៣:៥-៧។

កំណើតដំបូងគឺកើតពីទឹក។ គ្រូពេទ្យសរសៃប្រសាទកុមារ នៅសាកលវិទ្យាល័យ Allegheny បាននិយាយថាបុគ្គលម្នាក់ៗមានភាគរយខុសគ្នានៃរាងកាយរបស់ពួកគេដែលកើតពីទឹក។ ខណ:ពេលដែលកុមារនៅ ផ្ទៃពោះរបស់ម្តាយ ពួកគេអភិវឌ្ឍនៅក្នុងថង់ទឹក; ទោះបីជាសារធាតុរាវ amniotic មិនមែនជាទឹកតែមួយទេ ទឹកគឺជាផ្នែកមួយនៃ សមាសធាតុ។ នៅពេលដែលថង់ទឹកបែក ទារកកើតមក នោះគឺជាកំណើតទីមួយ។ កំណើតទីពីរគឺការផ្តល់ជីវិតដល់វិញ្ញាណរបស់អ្នកនៅពេលអ្នកបានទទួលព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ ហើយអ្នកត្រូវបានផ្តល់ការធានាការមានជីវិតដ៏អស់កល្បនៅស្ថានសួគ៌។

អំពើបាបជាហេតុផលធ្វើអោយមានសេចក្តីស្លាប់ខាងវិញ្ញាណ, **"ដូច្នេះ ដែលបាបបានចូលមកក្នុងលោកីយ៍ ដោយសារមនុស្សតែម្នាក់ ហើយក៏មានសេចក្ដីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្ដីស្លាប់បានឆ្លងរាលដាល ដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ ដ្បិតគ្រប់គ្នាបានធ្វើបាបហើយ"** -រ៉ូម ៥:១២។ ព្រះគម្ពីរយ៉ូហាន ៤:២៤ បានប្រាប់យើងថា, **"ព្រះគឺជាវិញ្ញាណ..."** ដូច្នេះ ដើម្បីអោយស្គាល់ ហើយថ្វាយបង្គំព្រះបាន មនុស្សត្រូវតែរស់ខាងវិញ្ញាណ។ តើវិញ្ញាណដែលស្លាប់អាចនឹងថ្វាយបង្គំព្រះដែលមានព្រះជន្មរស់បានទេ? គឺមិនអាចទេ។ ប៉ុន្តែនៅពេលដែលអ្នកប្រែចិត្ត ហើយជឿលើដំណឹងល្អ ការសុគត ការបញ្ចុះក្នុងផ្នូរ និងការរស់ឡើងវិញរបស់ព្រះយេស៊ូវ វិញ្ញាណរបស់អ្នកនឹងរស់ឡើងវិញ (កំណើតទីពីរ)។

វិញ្ញាណដែលមានជីវិតរបស់អ្នកស្តារទំនាក់ទំនងរបស់អ្នកជាមួយព្រះ ហើយអ្នកនឹងបានទៅនៅជាមួយព្រះនៅស្ថានសួគ៌។ លោកសាវកប៉ុលបានអះអាងថា, **"ដ្បិតខ្ញុំគ្មានសេចក្តីខ្មាស ចំពោះដំណឹងល្អនៃព្រះគ្រីស្ទទេ ពីព្រោះជាព្រះចេស្តានៃព្រះសំរាប់នឹងជួយសង្គ្រោះដល់អស់អ្នកណាដែលជឿ គឺដល់ទាំងសាសន៍យូដាជាដើម និងសាសន៍ក្រេកផង"** -រ៉ូម ១:១៦។ ព្រះគម្ពីរបានបញ្ជាក់យ៉ាងច្បាស់ថាមនុស្សទាំងអស់គឺមានបាប, **"ពីព្រោះគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ"** -រ៉ូម ៣:២៣។ ខ្វះគឺខ្វះ ទោះបីខំប្រឹងរស់ផែងយ៉ាងណាក៏ដោយ។ ព្រះគម្ពីរក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរអំពីថ្លៃឈ្នួលរបស់អំពើបាន, **"ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ចដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា"** -រ៉ូម ៣:២៣។ ដូច្នេះ មនុស្សម្នាក់ៗត្រូវបង់ថ្លៃសម្រាប់អំពើបាបរបស់ខ្លួន។ អ្នកមានជម្រើសពីរ៖ ទទួលយកការបង់ថ្លៃ អំពើបាបដែលបានផ្តល់ឱ្យអ្នកដោយព្រះយេស៊ូវ ឬអ្នកត្រូវបង់ថ្លៃសំរាប់អំពើបាបរបស់ខ្លួនដោយអណ្តាតភ្លើងដែលឆេះនៅអស់កល្បជានិច្ច។

---

**ការលះបង់ដ៏អស្ចារ្យបំផុត**

ព្រះយេស៊ូវគ្រីស្ទគឺជាព្រះដែលបានប្រសូតមកក្នុងសាច់ឈាម ទ្រង់ស្រឡាញ់មនុស្សដល់ម្លេះបានជាទ្រង់យាងមកផែនដីក្នុងទម្រង់ជាមនុស្សដើម្បីសុគតសម្រាប់អំពើបាបរបស់មនុស្សគ្រប់រូប។ **"ដែលទោះបើទ្រង់មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ។ គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង។ ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់ឈើឆ្កាងផង"** -ភីលីព ២:៦-៨។

ព្រះបានដើរចេញពីភាពអស់កល្បជានិច្ច ក្នុងទម្រង់ជាមនុស្ស ហើយរងទុក្ខទោសនៃអំពើបាបរបស់យើង។ ទ្រង់បានធ្វើដូច្នេះដើម្បីអោយគ្រប់គ្នាដែលជឿលើទ្រង់អាចឈានទៅរកភាពអស់កល្បជានិច្ចនៅក្នុងរូបអង្គទ្រង់ ព្រះនៅក្នុងសាច់ឈាម។ **"ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សំដែងមកនៅឡើយ ប៉ុន្តែ យើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង"** -១យ៉ូហាន ៣:២។

ព្រះយេស៊ូវសុខចិត្តសុគតជំនួសអ្នក ជាងចំណាយពេលអស់កល្បជានិច្ចនៅស្ថានសួគ៌ដោយគ្មានអ្នក។ គ្រិស្ទានដែលបានកើតជាថ្មីមិនមានសិទ្ធិអួតអាងចំពោះសេចក្តីសង្គ្រោះរបស់ពួកគេទេ។ វាមិនមែនដោយសារអំពើល្អដែលពួកគេបានប្រព្រឹត្តទេ។ គឺដោយសារព្រះគុណរបស់ព្រះវិញ! ទ្រង់បានធ្វើការ ហើយគ្រិស្ទានដែលបានកើតជាថ្មីបានទទួលរង្វាន់! សូមថ្វាយសិរីល្អដល់ទ្រង់! ការពិតនេះគឺជាភាពខុសគ្នារវាងសាសនាផ្សេងទៀត ជាមួយនឹងគ្រីស្ទានដែលបានកើតជាថ្មី។ **"ដ្បិតពីដើម យើងរាល់គ្នាក៏ជាមនុស្សឥតប្រាជ្ញា រឹងចចេស ហើយវង្វេងដែរ ទាំងបំរើសេចក្តីប៉ងប្រាថ្នា និងសេចក្តីសំរើបផ្សេងៗ ទាំងរស់នៅដោយសេចក្តីគំរក់ និងសេចក្តីឈ្នានីស យើងក៏គួរខ្ពើម ហើយបានស្អប់គ្នាទៅវិញទៅមកដែរ។ តែកាលសេចក្តីសប្បុរសរបស់ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង និងសេចក្តីស្រឡាញ់របស់ទ្រង់ដល់មនុស្សបានលេចមកឲ្យឃើញ នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញនៃព្រះវិញ្ញាណបរិសុទ្ធ ដែលទ្រង់បានចាក់មកលើយើងជាបរិបូរ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអង្គសង្គ្រោះនៃយើង'** -ទីតុស ៣:៣-៦។

---

**ការកើតខាងវិញ្ញាណ**

ផែនការដែលព្រះបានដាក់មកសម្រាប់សេចក្តីសង្គ្រោះដ៏អស់កល្បជានិច្ចគឺត្រូវការកើតជាថ្មី។ លោកសាវកប៉ុលបានមានប្រសាសន៍ទាក់ទងនឹងការនេះទៅកាន់អ្នកជឿនៅក្រុងអេភេសូរថា, **"ពីដើម អ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ"** -អេភេសូរ ២:១, **"ប៉ុន្តែ ព្រះដែលទ្រង់មានសេចក្តីមេត្តាករុណាដ៏លើសលប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំង ដែលទ្រង់មានដល់យើងរាល់គ្នាអ ក្នុងកាលដែលយើងនៅស្លាប់ក្នុងការរំលងនៅឡើយ នោះទ្រង់បាន<u>ប្រោសឲ្យយើងរាល់គ្នាបានរស់</u>ជាមួយនឹងព្រះគ្រីស្ទ គឺដោយព្រះគុណ ដែលអ្នករាល់គ្នាបានសង្គ្រោះ"** -អេភេសូរ ២:៤-៥។ ពាក្យថា **"ប្រោសឲ្យរស់"** មានអត្ថន័យនៃការធ្វើឱ្យមានជីវិតឡើងវិញ។ លោកសាវកប៉ុលបាននិយាយទៅកាន់ពួកអ្នកជឿទាំងនេះដើម្បីជួយពួកគេឱ្យយល់ថានឹងមានអ្វីកើតឡើងនៅពេលដែលពួកគេបានប្រែចិត្ត ហើយជឿទៅលើដំណឹងល្អ។ គាត់បាននិយាយអំពីរឿងនេះជាលក្ខណៈផ្ទាល់ខ្លួន។ គាត់បានប្រើពាក្យថា, **"អ្នក"**។ ពេលដែលអ្នកសុំព្រះយេស៊ូវធ្វើជាព្រះអង្គសង្គ្រោះរបស់អ្នក នោះវិញ្ញាណរបស់អ្នកនឹងរស់ឡើងវិញ គឺជាកំណើតទីពីរ! លោកសាវកប៉ុលបានពិពណ៌នាយ៉ាងច្បាស់អំពីកំណើតខាងវិញ្ញាណនៅក្នុង កូរិនថូសទី១

១៥៖៤៩-៤១: **“ឯព្រះអាទិត្យ នោះមានរស្មីម្យ៉ាងទៅ ព្រះចន្ទក៏មានរស្មីម្យ៉ាងទៅ ហើយផ្កាយក៏មានរស្មីម្យ៉ាងទៅ សូម្បីតែផ្កាយទាំងប៉ុន្មានសោត ក៏មានរស្មីខុសពីគ្នាដែរ។ សេចក្ដីដែលមនុស្សស្លាប់បានរស់ឡើងវិញ នោះក៏បែបដូច្នោះដែរ គេបានកប់ទៅជារូបកាយដែលពុករលួយ តែរស់ឡើងវិញជារូបកាយមិនចេះពុករលួយឡើយ។ បានកប់ទៅ ទាំងមានសេចក្ដីអាប់ឱន តែរស់ឡើងវិញ ទាំងមានសិរីល្អ បានកប់ទៅ ទាំងមានសេចក្ដីកំសោយ តែរស់ឡើងវិញ ទាំងមានព្រះចេស្ដា។ បានកប់ទៅជារូបកាយខាងសាច់ឈាម តែរស់ឡើងជារូបកាយខាងវិញ្ញាណវិញ បើមានរូបកាយខាងសាច់ឈាម នោះក៏មានរូបកាយខាងវិញ្ញាណដែរ។ ដូចជាសេចក្ដីដែលចែងទុក ពីលោកអ័ដាម ដែលជាមនុស្សមុនដំបូងថា «បានត្រឡប់ជាមានព្រលឹងរស់»តែលោកអ័ដាមក្រោយបង្អស់ ជាវិញ្ញាណដ៏ប្រោសឲ្យរស់វិញ។ ឯវិញ្ញាណមិនមែនកើតមុនទេ គឺជារូបសាច់ទេតើ រួចទើបមានវិញ្ញាណជាខាងក្រោយ។ មនុស្សមុនដំបូងកើតមកពីដី គឺធ្វើមកពីធូលីដី តែមនុស្សទី២ ជាព្រះអម្ចាស់ដែលចេញមកពីស្ថានសួគ៌វិញ។ ឯមនុស្សដែលកើតពីធូលីដីមកជាយ៉ាងណា នោះអស់អ្នកដែលកើតពីធូលីដី ក៏យ៉ាងនោះដែរ ហើយព្រះអម្ចាស់ដែលយាងមកពីស្ថានសួគ៌ ជាយ៉ាងណា ពួកស្ថានសួគ៌ក៏យ៉ាងនោះដែរ។ យើងក៏នឹងមានរូបរាងរបស់ព្រះអម្ចាស់ពីស្ថានសួគ៌ ដូចជាយើងមានរូបរាងរបស់មនុស្ស ដែលធ្វើពីធូលីមកដែរ”** (សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម)។

---

**ជីវិតកើតខាងវិញ្ញាណន្លាមៗ គឺការកើតជាថ្មី!**

**“គ្រាក្រោយដែលគេបញ្ជូនយ៉ូហានទៅឃុំហើយ នោះព្រះយេស៊ូវទ្រង់យាងមកក្នុងស្រុកកាលីឡេវិញ ព្រមទាំងប្រកាសប្រាប់ដំណឹងល្អពីនគរព្រះថា ពេលវេលាបានសំរេចហើយ នគរព្រះជិតមកដល់ ដូច្នេះ ចូរប្រែចិត្ត ហើយជឿដំណឹងល្អចុះ”**
-ម៉ាកុស ១:១៤-១៥។ លោកសាវកប៉ុលបានប្រាប់យើងនៅក្នុងព្រះគម្ពីររ៉ូមថា ជំនឿរបស់យើងនឹងបណ្ដាលឲ្យយើងមានបំណងប្រាថ្នាសំរាប់សេចក្ដីសុចរិត, **“បើមាត់អ្នកនឹងទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូវ ហើយអ្នកជឿក្នុងចិត្តថា ព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញ នោះអ្នកនឹងបានសង្គ្រោះពិត។ ដ្បិតយើងបានសុចរិតដោយមានចិត្តជឿ ហើយក៏បានសង្គ្រោះដោយមាត់ទទួលថ្លែងប្រាប់”** -រ៉ូម ១០:៩-១០។ ពេលដែលមនុស្សម្នាក់ប្រែចិត្តទៅរកព្រះ(ងាកចេញពីការមិនជឿ) នោះវិញ្ញាណបានកើតជាថ្មី, **“បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្ដីចាស់បានកន្លងបាត់ទៅមើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ”** -២ កូរិនថុស ៥:១៧។

ការផ្លាស់ប្តូរនេះត្រូវបានសម្រេចដោយ, **“...ការប្រែចិត្តទៅឯព្រះ ហើយពីសេចក្តីជំនឿជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទនៃយើងរាល់គ្នា”** -២ កូរិនថុស ៥:១៧។

*«ការប្រែចិត្តគឺជាការរកឃើញពីអំពើអាក្រក់នៃអំពើបាប ដែលជាការសោកស្តាយនូវអ្វីដែលយើងបានប្រព្រឹត្ត ហើយរិះរកវិធីដើម្បីបោះបង់វាចោល។ តាមពិត វាគឺជាការផ្លាស់ប្តូរជម្រៅនៃចិត្ត និងធ្វើឲ្យមនុស្សស្រឡាញ់អ្វីដែលធ្លាប់ស្អប់ ហើយស្អប់អ្វីដែលធ្លាប់ស្រឡាញ់។»*

---

**ដង្ហើមរបស់ព្រះនាំមកនូវជីវិត**

**“ព្រះយេហូវ៉ាដ៏ជាព្រះទ្រង់យកធូលីដីមកសូនធ្វើជាមនុស្ស ទ្រង់ផ្លុំខ្យល់ដង្ហើមជីវិតបញ្ចូលទៅក្នុងរន្ធច្រមុះ នោះក៏ត្រឡប់ជាមានព្រលឹងរស់ឡើង”** -លោកុប្បត្តិ ២:៧។ បន្ទាប់ពីព្រះហស្តរបស់ព្រះបានបង្កើតមនុស្សចេញពីធូលីដី ដង្ហើមរបស់ទ្រង់ដែលបានប្រទានជីវិតដល់លោកអ័ដាម។ ព្រះមិនបានបង្កើតដង្ហើមទេ គឺទ្រង់បានប្រទានដល់យើង! ពេលមនុស្សមានបាបអញ្ជើញព្រះយេស៊ូវមកធ្វើជាព្រះអង្គសង្គ្រោះរបស់ពួកគេ នោះព្រះវិញ្ញាណបរិសុទ្ធនឹងយាងចូលមកក្នុងជីវិតរបស់ពួកគេ។ ដោយសារតែព្រះវិញ្ញាណបរិសុទ្ធគឺជាវិញ្ញាណដែលមិនអាចមើលឃើញបាន គឺដូចជាខ្យល់អញ្ចឹង។ ទោះបីជាវាងាយស្រួលមើលភស្តុតាងនៃខ្យល់ក៏ដោយ អ្នកមិនអាចមើលឃើញខ្យល់ដោយខ្លួនឯងបានទេ។ ពេលអ្នកសិក្សាពីអត្ថន័យដើមនៃព្រះវិញ្ញាណបរិសុទ្ធ វាមានអត្ថន័យបង្ហាញថា « ដង្ហើមនៃព្រះ ដែលប្រោសឲ្យមានជីវិត ...»។

នៅពេលដែលមនុស្សមានបាបសុំឱ្យព្រះគ្រីស្ទយាងចូលមកក្នុងជីវិតរបស់ពួកគេ ដើម្បីធ្វើជាព្រះអង្គសង្គ្រោះរបស់ពួកគេ នោះព្រះវិញ្ញាណបរិសុទ្ធបានបញ្ចូលដង្ហើមជីវិតទៅក្នុងវិញ្ញាណស្លាប់របស់ពួកគេ។ ដូចជាដង្ហើមរបស់ព្រះបានផ្តល់ជីវិតដល់ព្រលឹងរបស់លោកអ័ដាម នោះដង្ហើមរបស់ទ្រង់ក៏នឹងធ្វើអោយវិញ្ញាណរបស់អ្នកបានរស់ឡើងវិញដែរ។ ពេលនោះ ពួកគេមានកំណើតទីពីរ ដែលធ្វើឱ្យពួកគាត់អាចទាក់ទងជាមួយព្រះ, **“ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ”** -រ៉ូម ៨:១៦។ ដូចជាស្លឹកឈើដែលប្រែពណ៌នៅរដូវកាល ជីវិតផ្លាស់ប្រែរបស់មនុស្សមានបាបគឺជាភស្តុតាងនៃការកើតខាងវិញ្ញាណរបស់ពួកគេ។ ផែនការដ៏អស់កល្បរបស់ព្រះសម្រាប់សេចក្តីសង្គ្រោះរបស់មនុស្សគឺជាអំណោយដែលមកពីព្រះ។ ដូច្នេះ វាសំខាន់ណាស់ ដែលអ្នកត្រូវជឿលើដំណឹងល្អសិន គឺតាមរយៈការប្រសូតរបស់ព្រះយេស៊ូវតាមរយៈស្ត្រីព្រហ្មចារី

ជីវិតដែលគ្មានបាបរបស់ទ្រង់នៅលើផែនដី (ព្រះនៅក្នុងសាច់ឈាម) ការសុគតរបស់ទ្រង់នៅលើឈើឆ្កាង ហើយជាពិសេសគឺការរស់ឡើងវិញរបស់ទ្រង់។ ព្រះគម្ពីរបានមានបន្ទូលថា, **"ព្រោះសេចក្ដីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះ នោះរមែងនាំឲ្យប្រែចិត្តឡើង ប្រយោជន៍ឲ្យបានសង្គ្រោះ ជាសេចក្ដីដែលមិនត្រូវស្តាយឡើយ តែសេចក្ដីព្រួយរបស់លោកីយ៍ នោះបង្កើតសេចក្ដីស្លាប់វិញ"** -២កូរិនថុស ៧:១០។

បើអ្នកស្ម័គ្រក្នុងការប្រែចិត្ត នោះអ្នកត្រូវតែបែចេញពីអំពើបាប ហើយអ្នកត្រូវដឹងថាមានតែព្រះយេស៊ូវមួយគត់ដែលអាចជួយជួយសង្គ្រោះអ្នកបាន ចូរអំពាវនាវដល់ទ្រង់នៅថ្ងៃនេះ ចូរសូមទ្រង់ធ្វើជាព្រះអង្គសង្គ្រោះរបស់អ្នក, **"ហើយគ្រប់គ្នា គឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ"** -រ៉ូម ១០:១៣។

ការអំពាវនាវដល់ព្រះ គឺការនិយាយទៅកាន់ទ្រង់តាមរយៈការអធិស្ឋាន សុំឱ្យទ្រង់អត់ទោសអំពើបាបរបស់អ្នក ហើយសូមស្វាគមន៍ទ្រង់មកនៅក្នុងចិត្តរបស់អ្នក ដើម្បីជួយអ្នកអោយរស់នៅក្នុងជីវិតដែលគាប់ព្រះហឫទ័យដល់ទ្រង់។

ការអធិស្ឋានខាងក្រោមគឺជាគំរូសំរាប់ការអធិស្ឋាន។ ចូរអ្នកបំពេញចន្លោះពេលអ្នកនិយាយដោយផ្ទាល់ជាមួយទ្រង់។

ឱព្រះអម្ចាស់អើយ ទូលបង្គំដឹងថា ទូលបង្គំជាមនុស្សមានបាប ដែលត្រូវកាត់ទោសទៅកាន់ឋាននរក។ ទូលបង្គំសូមព្រះអង្គអត់ទោសអំពើបានរបស់ទូលបង្គំផង។ ទូលបង្គំជឿថាព្រះយេស៊ូវជារាជបុត្រានៃព្រះ ដែលបានសុគតនៅលើឈើឆ្កាង ហើយបានរស់ឡើងវិញសម្រាប់ទូលបង្គំ។ សូមអភ័យទោសដល់ទូលបង្គំផង។ សូមយាងចូលមកក្នុងចិត្តរបស់ទូលបង្គំ ហើយជួយទូលបង្គំអោយរស់នៅប្រកបដោយជីវិតដែលគាប់ដល់ព្រះហឫទ័យទ្រង់។ ទូលបង្គំសូមទទួលយកទ្រង់ជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះផ្ទាល់ខ្លួនរបស់ទូលបង្គំ។ សូមអរព្រះគុណទ្រង់ដែលបានកត់ត្រាឈ្មោះរបស់ទូលបង្គំនៅក្នុង**សៀវភៅជីវិត**។ ទូលបង្គំសូមអធិស្ឋាននៅក្នុងព្រះនាមព្រះយេស៊ូវ អាម៉ែន។

## ភាពធានា

ព្រះវិញ្ញាណនៃព្រះដែលគង់នៅក្នុងអ្នកមិនចង់ឲ្យអ្នកឆ្ងល់ថាតើអ្នកពិតជាបានសង្គ្រោះសំរាប់ស្ថានសួគ៌ ឬក៏អត់។ ទ្រង់ចង់ឲ្យយើងដឹងថា យើងត្រូវបានលើកលែងទោសជារៀងរហូត ហើយមានកន្លែងទុកសម្រាប់យើងនៅស្ថានសួគ៌។

ទ្រង់ផ្តល់ឱ្យយើងនូវទំនុកចិត្តនេះនៅក្នុងព្រះបន្ទូលរបស់ទ្រង់, **"បើសិនជាយើងបានទទួលសេចក្តីបន្ទាល់របស់មនុស្សទៅហើយ នោះសេចក្តីបន្ទាល់របស់ព្រះក៏ប្រសើរជាងទៅទៀត ដ្បិតសេចក្តីបន្ទាល់របស់ព្រះគឺជាសេចក្តីដែលទ្រង់ថ្លែងប្រាប់ពីព្រះរាជបុត្រានៃទ្រង់។ អ្នកណាដែលជឿដល់ព្រះរាជបុត្រានៃព្រះ នោះមានសេចក្តីបន្ទាល់នៅក្នុងខ្លួនហើយ តែអ្នកណាដែលមិនជឿសោះ នោះឈ្មោះថា បានធ្វើឱ្យទ្រង់ទៅជាអ្នកកុហកវិញ ពីព្រោះមិនបានជឿដល់សេចក្តីបន្ទាល់ ដែលទ្រង់បានធ្វើពីដំណើរព្រះរាជបុត្រានៃទ្រង់។ នេះហើយជាសេចក្តីបន្ទាល់នោះ គឺថា ព្រះទ្រង់បានប្រទានជីវិតដ៏នៅអស់កល្បជានិច្ចមកយើងរាល់គ្នា ហើយជីវិតនោះ គឺនៅក្នុងព្រះរាជបុត្រានៃទ្រង់។ ឯអ្នកណាដែលមានព្រះរាជបុត្រា នោះក៏មានជីវិតដែរ តែអ្នកណាដែលគ្មានព្រះរាជបុត្រានៃព្រះទេ នោះគ្មានជីវិតឡើយ។ ខ្ញុំបានសរសេរសេចក្តីទាំងនេះ ផ្ញើមកអ្នករាល់គ្នាដែលជឿដល់ព្រះនាមព្រះរាជបុត្រានៃព្រះ ដើម្បីឱ្យអ្នករាល់គ្នាបានដឹងថា អ្នករាល់គ្នាមានជីវិតអស់កល្បជានិច្ចហើយ"** -១យ៉ូហាន ៥:៩-១៣។

(សូមមើលឃ្លាដែលមានបន្ទាត់ខាងក្រោម)

ប្រសិនបើអំពើល្អរបស់អ្នកអាចជួយសង្គ្រោះអ្នកបាន នោះអ្នកអាចនឹងបាត់បង់ម្តងទៀតដោយអំពើអាក្រក់ដែលអ្នកនឹងប្រព្រឹត្ត។ ប៉ុន្តែ ប្រសិនបើអ្នកបានកើតជាថ្មីដោយព្រះគុណនៃព្រះ សេចក្តីសង្គ្រោះរបស់អ្នកនឹងមានសុវត្ថិភាពជារៀងរហូត ដោយសារសេចក្តីមេត្តាករុណារបស់ព្រះ, **"នោះទ្រង់បានជួយសង្គ្រោះយើង មិនមែនដោយការដែលយើងបានប្រព្រឹត្តដោយសុចរិតនោះទេ គឺដោយសេចក្តីមេត្តាករុណារបស់ទ្រង់វិញ ដោយសារការសំអាតនៃសេចក្តីកើតជាថ្មី ហើយការប្រោសជាថ្មីឡើងវិញ នៃព្រះវិញ្ញាណបរិសុទ្ធ"** -ទីតុស ៣:៥។

ពេលដែលមនុស្សម្នាក់បានកើតមកក្នុងរូបកាយ ពួកគេមិនមានការកត់ត្រាអំពីអតីតកាលទេ។ នៅពេលដែលមនុស្សនោះបានកើតជាថ្មីខាងវិញ្ញាណ អំពើបាបរបស់ពួកគេនៅអតីតកាលត្រូវបានរលាយបាត់ទៅទាំងស្រុងនៅចំពោះព្រះនេត្ររបស់ព្រះ។ ខាងក្រោមនេះជាបទគម្ពីរមួយចំនួនដែលនឹងធ្វើឱ្យអ្នកមានអំណរ៖

**"ហើយព្រះវិញ្ញាណបរិសុទ្ធ ក៏ធ្វើបន្ទាល់ដល់យើងដែរ ដ្បិតក្រោយដែលទ្រង់មានព្រះបន្ទូលថា «ឯសេចក្តីសញ្ញា ដែលអញនឹងតាំងដល់គេក្រោយគ្រានោះ គឺថា អញនឹងដាក់ក្រឹត្យវិន័យអញនៅក្នុងចិត្តគេ ហើយនិងកត់ទុកនៅក្នុងគំនិតគេផង»។**

**នោះទ្រង់បានបន្ថែមនូវព្រះបន្ទូលនេះទៀតថា «អញនឹងលែងនឹកចាំពីអំពើបាប និងសេចក្តីទទឹងច្បាប់របស់គេទៀត»"** -ហេព្រើរ ១០:១៥-១៧។

**"ឯទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណា ទ្រង់បានដកយកអស់ទាំងការល្មើសនៃយើង ឲ្យឃ្លាតឆ្ងាយពីយើងយ៉ាងនោះដែរ"** –ទំនុកដំកើង ១០៣:១២។

**"ខ្ញុំនឹងរងទ្រាំចំពោះសេចក្តីគ្នាន់ក្នាញ់របស់ព្រះយេហូវ៉ា ពីព្រោះខ្ញុំបានធ្វើបាបនឹងទ្រង់ហើយ គឺនឹងរងទ្រាំដរាបដល់ទ្រង់កាន់ក្តីជំនួសខ្ញុំ ហើយបានសំរេចសេចក្តីយុត្តិធម៌ដល់ខ្ញុំ នោះទ្រង់នឹងនាំចេញមកឯពន្លឺ រួចខ្ញុំនឹងរំពឹងមើលសេចក្តីសុចរិតរបស់ទ្រង់"** -មីកា ៧:៩។

**"គឺអញ អញនេះហើយជាអ្នកដែលលុបអំពើរំលងរបស់ឯងចេញ ដោយយល់ដល់ខ្លួនអញ ហើយអញមិននឹកចាំអំពើបាបរបស់ឯងទៀតឡើយ"** -អេសាយ ៤៣:២៥។

**"នោះត្រូវដឹងថា អ្នកណាដែលនាំមនុស្សបាប ឲ្យត្រឡប់ពីផ្លូវវង្វេងមកវិញ នោះឈ្មោះថា បានជួយសង្គ្រោះព្រលឹង១ ឲ្យរួចពីសេចក្តីស្លាប់ ហើយក៏គ្របបាំងអំពើបាបជាអនេកអនន្តផង"** -យ៉ាកុប ៥:២០។

**"ដូច្នេះ ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឲ្យមានពេលលំហើយ មកពីចំពោះព្រះអម្ចាស់"** -កិច្ចការ ៣:១៩។

ប្រសិនបើអ្នកបានសុំព្រះជាព្រះអង្គសង្គ្រោះរបស់អ្នកនៅថ្ងៃនេះ សូមទាក់ទងមកយើងខ្ញុំជាមួយនឹងព័ត៌មានដែលបានផ្តល់នៅខាងក្រោម។ យើងរីករាយនឹងការសម្រេចចិត្តរបស់អ្នក ហើយរីករាយក្នុងការជួយដំរង់ផ្លូវអ្នកក្នុងជីវិតថ្មីជាមួយព្រះ។ សូមស្វាគមន៍មកកាន់គ្រួសាររបស់ព្រះ! ព្រះប្រទានពរអ្នក!

**"ដ្បិតព្រះបានបង្កើតអ្នករាល់គ្នាជាថ្មី មិនមែនពីពូជដែលតែងតែពុករលួយនោះទេ គឺពីពូជដែលមិនចេះពុករលួយវិញ គឺជាព្រះបន្ទូលដ៏រស់ ហើយនៅជាប់លាប់"** -១ពេត្រុស ១:២៣។

**កើតម្តងស្លាប់ពីរដង កើតពីរដងស្លាប់ម្តង :**

**និពន្ធដោយលោកបណ្ឌិត ម៉ៃ វ៉ាន់ហាន**

# ភាពអស់កល្បគឺជាពេលវេលាមួយដ៏យូរក្នុងការធ្វើខុស

យើងទាំងអស់គ្នាគឺជាការបង្កើតមកសំរាប់ការអស់កល្បជានិច្ច ទោះជឿ ឬមិនជឿ។ ភាពអស់កល្បរបស់អ្នកបានចាប់ផ្តើម នៅពេលនៃការចាប់កំណើតរបស់អ្នក។ ជាអកុសល ដោយមានការយល់ខុស និងការខកចិត្តយ៉ាងខ្លាំងក្នុងចំណោមសង្គម សាសនា មនុស្សជាច្រើនបានចាញ់បោកការកុហកថាជីវិតនឹងចប់នៅពេលពួកគេស្លាប់។ ការរងទុក្ខអស់កល្បគឺជាគ្រោះថ្នាក់ នៃការយល់ខុសក្នុងបញ្ហានេះ!

ព្រះដ៏ពិត និងមានព្រះជន្មគង់នៅស្ថានសួគ៌ ទ្រង់មិនសុខចិត្តឲ្យនរណាម្នាក់មានជោគវាសនាក្នុង ក្នុងការរងទុក្ខវេទនាដ៏អស់កល្បជានិច្ចនោះទេ។ សេចក្តីស្រឡាញ់របស់ព្រះចំពោះអ្នក គឺជាមូលហេតុដែលព្រះយេស៊ូវជាព្រះនៅក្នុងសាច់ឈាមបានយាងមកសុគតនៅលើឈើឆ្កាង រក្សាសេចក្តីពិតអំពីភាពអស់កល្បជានិច្ចនៅក្នុងព្រះគម្ពីរ ហើយជាមូលហេតុដែលសៀវភៅនេះនៅចំពោះអ្នក! ទាំងអស់នេះគឺសម្រាប់អ្នក! ព្រះយេស៊ូវបានភ្លក់សេចក្តីស្លាប់ ហើយបានរស់ឡើងវិញពីផ្នូរ ដោយគ្របបាំងការដាក់ទោសរបស់អ្នកសំរាប់អំពើបាប ប្រសើរជាងការចំណាយពេលអស់កល្បជានិច្ចនៅក្នុងស្ថានសួគ៌ដោយគ្មានអ្នក។

នៅក្នុងសៀវភៅនេះ អ្នកនឹងឃើញអ្វីដែលគម្ពីរចែងអំពីជីវិតបន្ទាប់ពីសេចក្តីស្លាប់។ យើងមិនដឹងថានៅពេលណាដែលសេចក្តីស្លាប់នឹងគោះទ្វារជីវិតរបស់យើងទេ; នេះប្រហែលជាឱកាសចុងក្រោយរបស់អ្នកក្នុងការធានាគោលដៅដ៏អស់កល្បរបស់អ្នកនៅស្ថានសួគ៌។ **“ចូរស្វែងរកព្រះយេហូវ៉ា ក្នុងកាលដែលអាចនឹងរកទ្រង់ឃើញ ហើយអំពាវនាវដល់ទ្រង់ ក្នុងកាលដែលទ្រង់គង់នៅជិតចុះ”** -១ពេត្រុស ៥៥:៦។

ទាក់ទងនឹងភាពអស់កល្បជានិច្ច ការដឹងពីអ្វីដែលព្រះបានមានបន្ទូលអំពីទិសដៅដ៏អស់កល្បរបស់អ្នក ហើយទទួលយកការផ្តល់ជូនរបស់ទ្រង់ដើម្បីឱ្យអ្នកមានជីវិតអស់កល្បជានិច្ច វាសំខាន់ខ្លាំងណាស់សម្រាប់អ្នក និងមនុស្សដែលអ្នកស្រឡាញ់។

**“ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ”** -យ៉ូហាន ៣:១៦-១៧។



The Wallace Legacy FOUNDATION

ព្រះយេស៊ូវមានព្រះបន្ទូលថា, **“ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ”** -យ៉ូហាន ១៤:៦។

www.rethinketernity.com

www.wlfpartners.com